# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែឧសភា លេខ ៥

ព. ស. ២៤៩៤ – គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ដ្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនាទឹកគ្រឹស្ដសាសនា ( សម្ដិសិទ លោកវេជ្ជបណ្ឌិតមីគូត៍ ) (តមក) . . . | លោក ភ័យ - ប៊ុក . . . . . . . | ៣២៣ |
| ពន្ធអាស៊ីទ្វីប (តមក) . . . . . . . . . . | លោក ភ័យ - ប៊ុក . . . . . . | ៣២៨ |
| បភាកថា . . . . . . . . . . . . . . . . | អាចារ្យ ខោល - ប្រាក់ . . . . . . | ៣៣៤ |

**ផ្នែកអក្សរសាស្ដ្រ**

| | | |
|---|---|---|
| សារលិខិតនៃលោកស្វាមីវិវេកានន្ទ (តបប់) | លោក ភ័ - ប៊ុក . . . . . . . . | ៣៤២ |
| ការបណ្ដុះនីស្ស័យ (តមក) . . . . . . . | ព្រះមហាឧត្ដមវិជ្ជា ប៊ុត - ប៉ម . . | ៣៤៧ |
| អំឡេណក - ស៊ម្ប៉ាណា . . . . . . . . . | លោកផេង - ដ្រីវ . . . . . . . | ៣៥៩ |
| សព្ទបាក់តប្រែជាខ្មែរ ( តមក ) . . . . . | លោក ម៉ុញ - តាគ្រី . . . . . . . . | ៣៦៨ |
| រឿងសាមកុក (តមក) . . . . . . . . . | ឧកញ៉ា គួ - កន . . . . . . . . | ៣៧៣ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . | – ឈឹម - ក្រសេម . . . . . | ៣៨៦ |

**កំណត់ទីនប្រវត្តិការណ៍**

| | | |
|---|---|---|
| ពិធីបុណ្យប្រគេនព្រហ្មទានចំពោះព្រះសង្ឃ ៩៨ រូប ដែលប្រឡងជាប់សញ្ញាប័ត្រ សាលាបាលី ជាន់ខ្ពស់ (តបប់ . . . . . . . . . . | សមាគមមិត្តសាលាបាលី . . . . | ៣៩៣ |


មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជារ . . . . . . . . . . . . . ១៤៥៛,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.


## TABLE DES MATIÈRES


| PARTIE RELIGIEUSE | | Pages |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur André Migot) | *M. RAY-BUC* | 323 |
| La Lumière de l'Asie (suite) .... | *M. RAY-BUC* | 328 |
| PABHAKATHA ............... | *Achar KHOL PRAK* | 334 |
| **PARTIE LITTERAIRE** | | |
| Message du Swami VIVEKANANDA | *M. RAY-BUC* | 342 |
| L'Education morale (suite).... | *Préah moha PEUNG-PAM* | 347 |
| Histoire d'Héléna-Simiana ...... | *M. PHENG-CHRIEU* | 359 |
| Recueil des mots traduits par la Commission Culturelle « suite »... | *M. MENH-NAKRY* | 368 |
| Histoire de SAMKOK (suite) .... | *Oknha NOU-KAN* | 373 |
| Histoire du Royaume du Cambodge (suite ................ | *Oknha CHHIM-KRASEM* | 386 |
| **NOTES ET CHRONIQUES** | | |
| Fête de la distribution des prix aux 88 bonzes lauréats du concours de sortie de l'Ecole Supérieure de Pâli suite et fin) ....... | *Association des Amis de l'Ecole de Pâli* | 393 |



Prix d'abonnement annuel comprenant 12 numéros: 145$00

# ពុទ្ធសាសនា និង គ្រិស្តសាសនា

## សន្និសិទលោកមីគូត៍

លោក ក៉យ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

ប្រែពីទស្សនាវដ្តី "ហ្វ្រង់អាស៊ី" ខែមិថុនាឆ្នាំ ១៩៥០

(តមក)

---

គេអាចពោលបានថា ពួកពុទ្ធមាមកជនមានបំណងទៅកាន់ព្រះនិព្វាន ដូចជាពួកគ្រិស្តសាសនិកជន មានបំណងទៅកាន់ជីវភាពប្រកបដោយអនន្តកាល តែធនុះពួកទីមួយមានពលភាពទ្វេឡើងបាន ដោយហេតុថា ក្នុងកិច្ចការទាំងនេះមិនត្រូវទុកចិត្តអ្នកដទៃ ក្រៅពីសេចក្តីព្យាយាមរបស់ខ្លួនទេ ។ ពួកពុទ្ធមាមកជនដឹងថាគ្មានទំនៀមទម្លាប់, ពលិកម្ម, ពិធីណា អាចមកជំនួសកំឡាំងវិរិយភាពនៃអាត្មាបានឡើយ មិនត្រូវរង់ចាំអាទិទេពណាមកជួយទេ; តែអាចយល់បានថា សម្បជានធម៌ដែលខ្លួនប្រព្រឹត្តនោះមុខជាមានផលក្នុងកាលជាអនាគត ហើយគ្មានបុណ្យវាសនា (Prédestination) នៃអាទិទេពណា អាចមកកំណត់នូវជោគវាសនានៃខ្លួនបានឡើយ ។

គេបានឃើញច្បាស់ចំពោះលទ្ធិនេះ ត្រង់ឧត្តមភាពប្រកបដោយសេចក្តីរឹងរូសជាអស្ចារ្យ ត្រង់សុភាពថ្លៃថ្នូរដោយយ៉ាងក្រៃលែង ចំពោះមនុស្សជាតិព្រមទាំងជាប្រភពនៃសេចក្តីសង្ឃឹមនឹងសុទិដ្ឋិនិយម (Optimisme) ។

បុគ្គលគប្បីជ្រាប់បានថា ព្រះពុទ្ធដែលយើងពណ៌នាខាងលើនេះ មានចរិយាខុសពីព្រះពុទ្ធ ដែលគេថាជាអ្នកមានមនោគតិ (Rêveur) ប្រកបដោយកោសល្ល: ជាអ្នកមជ្ឈធាតុនិយម (Sceptique) មានចរិយាមិនប្រាកដហើយជាអ្នកខ្ជិលច្រអូស ; ជីវភាពរបស់ព្រះអង្គតាំងពីដើមរហូតមក ជាហេតុបញ្ជាក់ឲ្យឃើញផ្ទុយគ្នានឹងគតិដែលពោលមិនពិតនោះ ។ ព្រះអង្គទ្រង់បានតស៊ូនឹងទុក្ខ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ; រួចដល់ព្រះអង្គទ្រង់ចូលកាន់អនុបាទិសេសនិព្វានធាតុ ព្រះជន្មគំរប់ ៨០ ព្រះវស្សា ទ្រង់បានបំពេញពុទ្ធកិច្ច ឥតមានពេលទំនេរ ទេសនាទូន្មានប្រដៅសព្វសត្វឲ្យកាន់តាមសាសនារបស់ព្រះអង្គ ហើយព្រះអង្គឈប់បង្អង់បំពេញតាមពុទ្ធានុស័យ លុះត្រាតែព្រះអង្គហត់នឿយលំបាកជាខ្លាំង ទ្រង់ឈប់សម្រាកនៅតាមមាត់ផ្លូវ ។ ព្រះអង្គបានទូន្មានសាវ័ករបស់ព្រះអង្គនូវវិរិយភាព និងការតស៊ូបំពោះបាបអកុសល ហើយព្រះពុទ្ធសាសនា គឺជាសាលាមួយដែលបង្រៀនឲ្យមនុស្សមានថាមភាពយ៉ាងមោះមុត និងញាណប្រកបដោយវិសារទភាព (audacieux) ។ តើជាមនោគតិបុគ្គលឬ? ព្រះអង្គដែលប្រទានឲ្យដល់ពួកសាវ័ករបស់ព្រះអង្គថា យើងដែលបានឲ្យនាមខ្លួនយើងថា "យុទ្ធិកបុរស, យុទ្ធិកបុរស" ដូចនេះ ព្រោះយើងជាអ្នកតស៊ូដើម្បីគុណធម៌យ៉ាងឧត្តម ដើម្បីដំកល់

ទុកនូវវិរិយភាពដ៏ថ្លៃថ្លា ដើម្បីសម្រេចនូវគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់; ព្រោះហេតុដូចនេះ បានជាយើងឲ្យនាមខ្លួនយើងថា យុទ្ធិកបុរស"(១) ។

ដែលខ្ញុំទើបនឹងពណ៌នាជំរាបលោកអ្នក នាំឲ្យលោកអ្នកយល់ថា ព្រះពុទ្ធសាសនាមានលក្ខណៈពិសេស ដែលជាហេតុឲ្យមានសភាពផ្សេងគ្នាពីសាសនាដទៃ ៗ ដូចជាបញ្ហាខាងសទ្ធា ។

ចំណែកខាងសាសនា ដែលផ្សាយចេញពីគម្ពីរគ្រិស្ត, សាសនាស៊ុយដាអ៊ិស្ម (Judaïsme), គ្រិស្តសាសនា, សាសនាឥស្លាម មានន័យដូចគ្នានឹងព្រហ្មញ្ញសាសនា ដែលសិទ្ធិសាសនៈតាំងនៅបានគង់សាកលលោកគឺមកពីការប្រសិទ្ធិនៃអាទិទេព ដែលមានសំដែងក្នុងសៀវភៅពិសិដ្ឋៈ គម្ពីរគ្រិស្ត (Bible), គម្ពីរមហាម័ត (Coran), គម្ពីរវេទ (Véda) ។ គឺជាសព្ទពោលនៃអាទិទេព ជាពាក្យសច្ចៈដ៏ប្រណិត ហើយបើទុកជាគំនិតនោះមានសភាពផ្ទុយគ្នានឹងវិចារណញ្ញាណ នឹងសច្ចៈដែលមានប្រវត្តិសាស្រ្តជាឡាក់គោលសទ្ធិកបុរសមិនអាចនឹងជជែកបាន ។ ពួកកាតូលិកសង្គមអាចយល់វែងឆ្ងាយជាងនេះទៅទៀត ដោយសង្គមនេះទុកខ្លួនជាជាអ្នកមានឯកសិទ្ធ ក្នុងកិច្ចបកប្រែគម្ពីរពិសិដ្ឋទាំងប៉ុន្មានដោយត្រឹមត្រូវជាប្រណិត ។ ម្យ៉ាងទៀត មានសាសនជនកបុរសខ្លះ បានតាំងខ្លួន ឬ មានសាវកខ្លួនយល់ថា ខ្លួនជាអវតារនៃ

---

១ អង្គុត្តរនិកាយ ។

អាទិទេព ។ ចំណែកខាងព្រះពុទ្ធសាសនាគ្មានគោលការណ៍បែកខាងលើនេះសោះឡើយ ។

ឯព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មិនដែលតាំងព្រះអង្គជាបេសកបុរស ឬជាព្រះរាជបុត្រដែលអាទិទេពឲ្យមកផ្សាយសាសនានោះឡើយ ; តែព្រះអង្គបានផ្សាយនូវសច្ចជាបឋមចំពោះប្រទេសឥណ្ឌា មិនមែនដោយហេតុជំនឿនូវគម្ពីរពិសិដ្ឋ ឬដោយសំឡេងអាទិទេពអង្គណាមួយឡើយ គឺដោយវិចារណញ្ញាណ និងដោយការពិសោធន៍ជាឯកភាពរបស់ព្រះអង្គ ។ ជំនឿពុទ្ធសាសនា គឺជាការជឿជាក់ចំពោះមហាបុរសដែលទ្រង់បានស្វែងរកឃើញមគ្គសច្ច គឺផ្លូវដែលនាំទៅកាន់ទីរំលត់ទុក្ខ ។ ព្រះអង្គជាមគ្គុទ្ទេសក៍គ្រាន់តែជាអ្នកបង្ហាញផ្លូវឲ្យយើងដើរ តែស្រេចនឹងយើងព្យាយាមដើរតាមព្រះអង្គ ដោយប្រើវិធីពិសោធន៍ចំពោះខ្លួននូវវិធានការដែលព្រះអង្គបានបញ្ញត្តទុកមកដើម្បីនឹងសម្រេចនូវលទ្ធផលនោះ ។ ព្រះអង្គទ្រង់មិនបានដាក់កំហិតបង្ខំឲ្យប្រតិបត្តិតាមលទ្ធិណាមួយឡើយ ។ ព្រះអង្គមិនឲ្យយើងជឿដោយឥតពិចារណានូវឱវាទ ដែលព្រះអង្គបានព្រះរាជទានដោយអាងថាយើងជឿព្រោះព្រះអង្គបានសំដែងនូវធម៌នោះ ។ យើងត្រូវតែយកពុទ្ធោវាទនោះមកពិសោធន៍មើលខ្លួនយើង, សឹមយើងជឿព្រះអង្គជាខាងក្រោយ ។ ជំនឿនោះគឺជាការព្រមព្រៀងសុខចិត្តពេញលក្ខណៈដែលកើតឡើង មិនមែនដោយការព្យាយាមខាងផ្លូវ

ប្រាជ្ញាបន្តិចបន្តួចទេ គឺដោយសមាធិចិត្តប្រកបដោយវិរិយភាពដ៏សុខុម គឺការពិសោធន៍ពិតប្រាកដខាងធម៌បរមត្ថ ដែលមានសភាពជ្រាលជ្រៅពន់ពេក ។ ជំនឿនេះបានដឹកនាំឲ្យពួកខាងបស្ចិមប្រទេសចូលកាន់ព្រះពុទ្ធសាសនា ដោយមានសេចក្ដីនឿយណាយចំពោះការដាក់កំហិតបង្ខំឲ្យប្រតិបត្តិតាមលទ្ធិនោះៗ ដែលមានសភាពមិនស្របគ្នានឹងវិចារណញាណឬមនោគតិរបស់ខ្លួន ហើយមានសភាពសាបរលាបជាច្រើនសតវត្សមកហើយ ។

គេបានសន្ទនាដេញដោលគ្នាដើម្បីនឹងចង់ដឹងច្បាស់ថា ព្រះពុទ្ធសាសនាជាទស្សនវិជ្ជា ឬជាសាសនវិជ្ជា ? ។ បញ្ហានេះនឹងអាចពោលបានចំពោះតែពួកខាងបស្ចិមប្រទេស ។ ឯពួកខាងបូព៌ាប្រទេស បញ្ហានេះ មិនអាចកើតមានឡើយ ។ មានតែពួកខាងបស្ចិមប្រទេសទេ ដែលគេយល់ថាទស្សនវិជ្ជាជាសាខានៃវិជ្ជាទាំងឡាយ ឯទស្សនវិទូជាបុគ្គលសាមញ្ញ ច្រើនជាពួកមន្ត្រីដែលបានសិក្សានូវលទ្ធិមួយ ក្នុងវិជ្ជាស្ថាន ហើយដល់វិលត្រឡប់ទៅគេហដ្ឋានវិញ រស់នៅធម្មតាដូចពួកសារការី (notaire) ឬពួកទន្តពេទ្យរបស់ខ្លួនដោយយល់ថាលទ្ធិដែលបានសិក្សានោះមិនអាចជួតជ្រាបដល់ជីវភាពខាងក្នុង ឬប្រែចិត្តគំនិតលោកសោះឡើយ ។ មានតែខាងបស្ចិមប្រទេសទេ ដែលគេទុកសាសនាជាបន្ទប់មួយតូចដែលគេបិទទ្វារជាមុនទើបឲ្យប្រតិបត្តិការជាខាងក្រោយ ។

(មានត)

ពន្លឺអាស៊ីទ្វីប

# វគ្គទី ៦

La Lumière de l'Asie

## លោកស៊ើរ-អេតវិនអារណូលដ៍ តែង

លោកហ៊ុយ-ប៊ុក ក្រមការ ប្រែប្រៀបរៀង

(តមក)

---

សីលព្វតបរាមាសៈ ស្រែកទៅរកព្រះបរមពោធិសត្វថា “ម្ដេចក៏ព្រះអង្គហ៊ានរកធម៌នេះ ព្រះអង្គត្រូវលះបង់នូវគម្ពីរ, បណ្ដេញចេញពពួកទេវតា ឥន្ទ្រ ព្រហ្ម, បង្គាប់ឲ្យពួកភិក្ខុសង្ឃចេញពីវត្តអារាម ហើយបំបាត់នូវច្បាប់វិន័យដែលប្រកាសឲ្យគេចិញ្ចឹមព្រះសង្ឃ ហើយដែលជាប្រធាននៃព្រះរាជអាណាចក្រទាំងអស់ក្នុងលោក” ។ ព្រះពោធិសត្វត្រាស់តបទៅសីលព្វតបរាមាសៈវិញថា: “ដែលឯងសូមឲ្យយើងបំបាត់នោះ គឺជាទម្រង់នៃសត្វដែលជាអនិច្ចតាធម៌ទេ, តែសច្ចធម៌ស្ថិតនៅជានិច្ច; ឲ្យឯងចូលទៅក្នុងសហភាពអន្តរការរបស់ឯងចុះ” ។ រួចមេប្រវ័ញ្ចន៍យ៉ាងក្លាហានមកដល់ គឺកាមៈជាស្ដេចខាងតណ្ហាដែលមានឫទ្ធានុភាពអាចត្រួតត្រាដល់ទៅពពួកទេវតាឥន្ទ្រព្រហ្មផងទៀត ជានាយកលើកាមគុណប្រាំក្នុងលោក, ជាមហាក្សត្រិយ៍សោយរាជ្យនៅព្រះរាជអាណាចក្រនៃកិលេសគ្រប់យ៉ាង ។ កាមៈមានភ័ក្ត្រស្រស់ស្រាយ

ចូលមកក្រោមព្រះមហាពោធិ, ស្ពាយលើស្មានូវសរលាបលនដោយមាសល្អ មានខ្សែក្រងជាប់ជាក្បុប្ផាក្រហមអស្ចារ្យ ហើយទឹងសរនៃតណ្ហាដែលខាងចុងមានអណ្តាតភ្លើងព្រំសម្រាប់ដុតពោលពលនូវហទយ-វត្ថុ ហើយធ្វើចិត្តឲ្យអន្ទះអន្ទែងដូចជាលំពែងចាក់ ដែលគេលាបស្នាក់ដោយឧសថពិស ; ហើយនៅជុំវិញកាម: មានរូបនិមិត្តស្ត្រីភាពជាច្រើន មានរូបរាងទ្រង់ទ្រាយស្អាតស្អំជាទីទស្សនីយភាព ហើយមានបបូរមាត់ជាទិព្វ បញ្ចេញសព្ទសូរសំឡេងស្នេហាអាឡោះអាល័យជាច្រើនប្រការ, ព្រមទាំងថ្ងូងអត្តក្កុងទ្រកថាពីកាមរាគ, មានភ្លេងតូរ្យតន្ត្រីមានសព្ទពីរោះអស្ចារ្យ ហើយមើលមិនឃើញ ជានាមធម៌ធ្វើឲ្យនិសា (យប់) ស្ងាត់ស្ងៀម រង់ចាំសវនាសំឡេងទាំងនោះ នឹងធ្វើឲ្យតារាឬព្រះចន្ទឈប់សញ្ចរលើអាកាស រង់ចាំស្ដាប់សព្ទប្រៀងទំនុកត្រេកត្រអាលជាច្រើនប្រការ ចំពោះព្រះបរមពោធិសត្វ ពាក្យពោលពីកាម-តណ្ហាដែលព្រះអង្គទ្រង់មិនគួរបោះបង់ចោល ព្រោះជាទីនិយមនៃសត្វលោកក្នុងត្រៃភព, គ្មានអ្វីប្រសើរជាងសុជនប្រោះព្រំដោយគន្ធរសផ្កាយក្រអូបឈ្ងុយឈ្ងប់ នៃនារីដែលមានរូបរាងស្អាតល្អផូរផង់ត្រចះត្រចង់គួរឲ្យចេតនាពន់ពេក ហើយលះបង់នូវរូបនោះ បូជាជាអហំការចំពោះព្រះអង្គតាមព្រះទ័យ ឬ គ្មានវត្ថុអ្វីវិសេសជាងចុងសុជនមានពណ៌កុលាប ជាទីពេញចិត្តនៃតណ្ហា; មែនហើយនៅក្នុងលោកសន្និវាសនេះ

គ្មានអ្វីយកមកប្រៀបធៀបនឹងទ្រង់ទ្រាយដ៏វិចិត្រ ដែលមានសណ្ឋានគិនភាគលាយចំរុះរំលេចពណ៌គួរជាទីរមិលមើល កើតដោយទស្សនីយារម្មណ៍នៃកាយសិល្បៈ ប្រកបតាមក្បាច់ធម្មជាតិរចនាជាតិយ្យោភាពរបស់ស្រីដែលជាទីគាប់ចិត្តនោះឡើយ ! ។ កាយសិល្បៈ មានរូបឆោមលោមពណ៌ ដែលបញ្ចេញសព្ទសំឡេងស្វាត់ពុំញាប់ញ័រពីចិត្តមួយទៅចិត្តមួយ, ធ្វើឲ្យលោហិតហៀរហូរឡើង ព្រមទាំងចិត្តគោរពយ៉ាងមាំប្រកបដោយឆន្ទៈយ៉ាងក្លាហាន ដោយយល់ថា នេះជាវត្ថុវិសេស នេះជាស្ថានសួគ៌ដែលសត្វលោកទាំងអស់ តែងពេញចិត្តក្រេបនូវកាមារម្មណ៍សប្បាយត្រេកត្រអាលជាមួយនឹងពួកទេវតា ។ ឱជនសាងបុរសដ៏ឧត្តមនឹងមហាពជអើយ, នេះជាដង្វាយដ៏ថ្លៃថ្លាលើសដង្វាយទាំងអស់ក្នុងលោកនេះ មានសភាពផ្លាស់ប្តូរថ្មីជានិច្ច បើទុកជាវត្ថុទាំងនោះឲ្យទុក្ខទោសមួយពាន់ដង ក៏គួរព្រះអង្គទទួលដោយព្រះទ័យរីករាយពេញចិត្ត ។ តើអ្នកណាអាចថាទុក្ខព្រួយយ៉ាងណាកើត បើអវយវៈដ៏ទន់ល្វន់ល្វាសមកឧបរិតរួត ធ្វើឲ្យជីវិតរបស់ខ្លួនលាយប្រមូលទៅជាសព្ទសូរសុខស្រួលគួរស្រើបស្រាលសប្បាយ ព្រមទាំងព្យួរសំឡេងខ្លួរទ័រគឹកកងលាន់រំពងពេញមហាមេឃទាំងមូល នូវការថ្នាក់ថ្នមបីបមបើបដូច្នេះ? នេះហើយចំរៀងនៃរូបនិមិត្តរបស់នារីទាំងនោះ ដែលបញ្ចេញអាកប្បកិរិយាអវយវៈបុកពាជាអ្នកពេញចិត្តខាងកាមទេព, ដែលមានចក្ខុភ្លឺចាំងដោយ

ភ្លើងពតៈ ព្រមទាំងបបូរមាត់ញញឹមស្រស់គួរឲ្យចង់ជញ្ជក់ត្រេកត្រអាល ពន់ពេក ; ហើយរូបនិមិត្តទាំងនោះ បានរាំរែករាយសប្បាយដោយកិលេសកាម បានបង្ហាញនូវអាការៈនៃត្រគៀកមួយចំហៀង កំរើកជារបាំដូចជាបទចម្រៀងព្រមទាំងសូរសៀង អវយវៈដ៏ទន់ដូចជាក្រពុំផ្ការៀបនឹងបើកស្រទាប់រីកចេញរុងរឿង បញ្ចេញពណ៌សម្បុរស្រស់ស្រើបស្រួល តែលាក់បិទបាំងនូវទហយវត្ថុនៅឡើយ ៗ គ្មានវត្ថុអ្វីមានសភាពជាសុភនិមិត្តល្អ ហើយធ្វើឲ្យចក្ខុទស្សនាដោយអារម្មណ៍ជាទីពេញចិត្តជាងនាងរបាំក្នុងពេលរាត្រីនោះ ដែលចូលទៅស្និតជិតព្រះបរមពោធិ-សត្វ ៗ នាងក្រោយស្អាតល្អជាងនាងមុនពោលទៅកាន់ព្រះអង្គថាៈ " ឱព្រះសិទ្ធត្ថដ៏ឧត្តម ! ខ្ញុំព្រះអង្គសូមប្រគល់កាយថ្វាយជីវិតចំពោះទ្រង់, សូមទ្រង់មេត្តាជញ្ជប់នូវមាត់ខ្ញុំព្រះអង្គ ព្រមទាំងក្រេបយកនូវឱជារសនៃយុវភាពរបស់ខ្ញុំព្រះអង្គ " ៗ ចំណែកខាងព្រះបរមពោធិ-សត្វ ព្រះអង្គមានព្រះទ័យនឹងឥតកម្រើក ហើយកំកាមៈបានតម្កើងធ្ជ័យពួកស្រីរបាំបៀសចេញពីទីនោះទៅ ៗ ស្រាប់តែមានទម្រង់មួយថ្មីជារូបស្រីស្អាតស្រស់ជាងនាងមុននោះទៅទៀត, ចូលទៅក្នុងខ្លួនជាព្រះនាងយសោធរា ៗ ចក្ខុខ្មៅហើយទឹកនេត្រហូរស្រស្រាក់ស្រោចស្រប់ក្ព្រាពោលពាក្យស្នេហាដ៏ពីរោះពិសាទៅកាន់ព្រះអង្គ មានអវយវៈលើកឡើងបញ្ចេញអាកប្បកិរិយាព្រួយទុក្ខលំបាកដ៏ខ្លាំងក្លា សព្ទសូរហាសៀងថ្ងូរ

វង់ ហើយក៏រូបនិមិត្តស័ក្តិសមនោះ បានពោលទូលព្រះបរមនាមនៃព្រះពោធិសត្វ ហើយរៀបរាប់ថា: "ឱព្រះអង្គម្ចាស់ខ្ញុំអើយ ! ខ្ញុំព្រះអង្គមុខជានឹងក្ស័យជីវិត ដោយប្រាសព្រាត់ពីព្រះអង្គក្នុងកាលឥឡូវនេះ; តើព្រះអង្គអាចទ្រង់ព្រះតំរិះថា : មានមេឃឯណាដែលមានសភាពសោភាល្អត្រចះត្រចង់ជាងមេឃា ដែលព្រះអង្គនឹងខ្ញុំព្រះអង្គធ្លាប់ទស្សនានៅមាត់ស្ទឹងកោហិនី, នៅមហាប្រាសាទដែលជាទីត្រេកត្រអាលនោះឡើយ, ទីប្រាសាទដែលខ្ញុំព្រះអង្គបានទុក្ខលំបាកជាច្រើនឆ្នាំដោយរង់ចាំព្រះអង្គៗបោះបង់ចោលខ្ញុំព្រះអង្គស្រឡះ, សូមព្រះអង្គស្តេចយាងត្រឡប់វិលទៅមហាប្រាសាទវិញ, សូមទ្រង់វិលវិញកុំខាន ៗ យ៉ាងណាក៏ដោយសូមព្រះអង្គជញ្ជាប់នូវបបូរមាត់ខ្ញុំព្រះអង្គ ហើយសូមទ្រង់ព្រះរាជានុញ្ញាតឲ្យខ្ញុំព្រះអង្គផ្អែកទៅលើព្រះឧរព្រះអង្គ, ចិត្តខ្ញុំព្រះអង្គដែលប្រាថ្នានោះនឹងស្ងប់ស្ងាត់ទៅវិញមិនខាន ៗ ឱព្រះអង្គ ! សូមទ្រង់ឈ្វេងព្រះនេត្រមកខ្ញុំព្រះអង្គ, តើខ្ញុំព្រះអង្គ មិនមែនជាព្រះនាងដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យទេឬ? ៗ ព្រះបរមពោធិសត្វតបទៅនឹងនារីនិមិត្តនោះវិញថា "ចំពោះសេចក្តីមេត្តាទៅកាន់ព្រះនាងជាអគ្គជយា ដែលនាងប្រែសប់ប្រែតស្ថានរូបទ្រង់ទ្រាយឲ្យដូចនេះ, ឱរូបនិមិត្តអើយ, កលកិច្ចនាងឯងឥតប្រយោជន៍, គ្មានផល ; យើងមិនមែនពោលពាក្យលាមកអប្រិយទៅកាន់នាងទេ, នាងចេះនិមិត្តរូបល្អស្អាតម៉្លេះ ដូចជារូបភាព

គួរជាទីពិតពិលរមិលមើលក្នុងលោក, ចូលទាន់រលាយទៅក្នុងអនិច្ចតាភាពនៃលោកចុះ" ។ រូបមានសត្វស្វារលាន់ញាំពងក្នុងវនប្រទេស ហើយពួកនារីនិមិត្តនោះចាកចេញកាន់ទង់ជ័យក្តីដូចអគ្គី ហើយស័ត្វស្វាកំប្រាងរឹងប៉ះសាច់ដូចជាចំហាយត្រចះត្រចង់ព្រោងព្រាត, រលាយបាត់សាបសូន្យពីទីនោះទៅ ។

តមក, នៅកណ្តាលមេឃងងឹតចុះអ័ព្ទ ហើយទឹងសូរសត្វព្យុះសង្ឃរាយ៉ាងខ្លាំង, ក្នុងបំណោមពួកអកុសលទាំងដប់ប្រការ មានអកុសលឯទៀតជាច្រើនដែលនៅពីក្រោយតទៅទៀត ។ បឋម គឺបដិឃៈ (សេចក្តីស្អប់) មានដើមទ្រូងពស់ពែនព័ទ្ធជុំវិញ ហើយពស់នោះដញ្ជប់នូវទឹកដោះជាថ្នាំពុលដែលចេញពីដោះទាំងគូ ហើយពោលពាចាដ៏លាមកជាយ៉ាងក្រៃលែង ព្រមទាំងសំដែងនូវសេចក្តីក្រោធដ៏ពន្ទឹក ។ បដិឃៈនេះ មិនអាចធ្វើឲ្យព្រះទ័យព្រះពោធិសត្វកម្រើកញាប់ញ័របានឡើយ ។ ព្រះពោធិសត្វបានទតទៅចំបដិឃៈៗ ក៏ស្ងៀមស្ងាត់, បបូរមាត់ដែលធ្លាប់តែចេញសំដីអសប្បុរសក៏ស្ងប់, ហើយពស់ខ្មៅទាំងនោះក៏បញ្ចូលចង្កូមទៅវិញ ។ រូបតមកបានចេញរូបរាគៈ, ជាបាបអកុសលនាំឲ្យកើតនូវកាមារម្មណ៍ ហើយមានប្រាថ្នាចង់ក្របយករសជាតិក្នុងពិភពលោក, គ្រប់រសនៃខ្លួនឯង ។

(មានត)

# បាឋកថា

## លោកអាចារ្យ ខៀវ - ប្រាក់ វត្តលង្កា ក្រុងភ្នំពេញ

ទេសនាតាមវិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ៣ រោច ខែស្រាពណ៍

ឆ្នាំកុរឧត្តមស័ក ព. ស. ២៤៩ (៣-១០-៤៣)

---

នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យដោយគោរព ។

បន្ទាប់អំពីបទនមស្ការនេះទៅ ខ្ញុំសូមសំដែងធម៌ទេសនាតាមសមគួរដល់កាលវេលា ។

ធម្មតាមនុស្សក្នុងលោក ច្រើនណាស់ចូលចិត្តភ្លឺ មិនសូវចូលចិត្តងងឹតទេ, ដោយហោចទៅ សូម្បីតែមនុស្សមានភ្នែកខ្វាក់ក៏ចូលចិត្តភ្លឺដែរ; ព្រោះពន្លឺអាចបំភ្លឺឲ្យមើលវត្ថុគ្រប់យ៉ាងបាន ។ ហេតុនោះ បានជាព្រះអង្គមានព្រះភាគទ្រង់ត្រាស់សំដែងទុកក្នុងគម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាតថា: ពន្លឺនេះជាធម្មជាតិយ៉ាងប្រសើរវិសេសក្នុងលោក អាចញុំាងប្រយោជន៍គ្រប់យ៉ាងឲ្យសម្រេចបាន ។

ពន្លឺនោះមាន ៤ យ៉ាង គឺ:

១ – ពន្លឺព្រះអាទិត្យ ;

២ – ពន្លឺព្រះចន្ទ ;

៣ – ពន្លឺភ្លើង ;

៤ – ពន្លឺគឺប្រាជ្ញា ។

សូមអធិប្បាយអំពីពន្លឺទាំង ៤ នេះដោយសង្ខេបថា :

**ព្រះអាទិត្យ** មានអំណាចផ្ទុះពន្លឺឲ្យភ្លឺទៅដោយខ្លួនឯងបានតែក្នុងវេលាថ្ងៃប៉ុណ្ណោះ; មិនអាចផ្ទុះបំភ្លឺក្នុងវេលាយប់បានឡើយ ។

**ព្រះចន្ទ្រ** មានអំណាចផ្ទុះពន្លឺឲ្យភ្លឺបានតែក្នុងវេលាយប់ប៉ុណ្ណោះ មិនអាចនឹងផ្ទុះបំភ្លឺក្នុងវេលាថ្ងៃបាន ។

**ភ្លើង** មានអំណាចផ្ទុះបំភ្លឺទៅបានតែក្នុងពេលដែលគេបង្កាត់បុអុជប៉ុណ្ណោះ មិនអាចនឹងផ្សាយរស្មីឲ្យភ្លឺទៅក្នុងទីដទៃៗ បានឡើយ ។

បណ្ដាពន្លឺទាំង ៣ ដែលបានពណ៌នាមកនេះ នឹងបញ្ចេញពន្លឺរស្មីទៅបានតែទីណាដែលមានឧកាសល្មមប៉ុណ្ណោះ តែទីណាដែលជ្រៅកំបាំង ពន្លឺទាំង ៣ នេះមិនអាចនឹងផ្សាយទៅបាន ។

**បញ្ញា** ជាពន្លឺមួយវិសេសជាងពន្លឺទាំង ៣ នោះ ព្រោះអាចផ្ទុះបំភ្លឺទៅកាន់ទីឆ្ងាយឬទីជិត ទីជ្រៅឬទីកំបាំងបាន ។

កែវស្ទង់សម្រាប់ស្ទង់នូវរបស់ឲ្យដឹងចំនួនថាប៉ុណ្ណោះប៉ុណ្ណោះយ៉ាងណា បញ្ញាសម្រាប់លៃស្ទង់មើលហេតុការណ៍អាក្រក់ល្អបានទាំងអស់, មិនមានទើសទាល់ក យ៉ាងណានោះដែរ ; តួយ៉ាងដូចជាសម្បត្តិស្ថានសួគ៌ នឹងស្ថានព្រះនិព្វាន បើក្រៅតែអំពីបញ្ញាហើយ មិនអាចនឹងបញ្ចាំងបានឡើយ ។

ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនថាជាតិណា សាសន៍ណា ឬភាសាណាទេ, សុទ្ធសឹងតែមានសេចក្ដីប្រាថ្នាចង់បានបញ្ញាគ្រប់ៗគ្នា ប៉ុន្តែសេចក្ដីប្រាថ្នានោះ ជួនកាលក៏បានសម្រេច ជួនកាលក៏មិនបានសម្រេច ព្រោះបុគ្គលខ្លះចង់បានបញ្ញា ហើយខំប្រឹងប្រែងបណ្ដុះផ្សំពូជបញ្ញានោះឲ្យកើតឡើង បុគ្គលខ្លះចង់បានបញ្ញាដូចគេឯងដែរ ប៉ុន្តែជាមនុស្សខ្ជិលច្រអូស មិនខំប្រឹងប្រែងផ្សំពូជបញ្ញានោះឲ្យកើតឡើងទីទៃគេទេ ។

ហេតុនាំឲ្យកើតបញ្ញាមាន ៣ យ៉ាង គឺ:

១ – បញ្ញាកើតអំពីគិត ;

២ – បញ្ញាកើតអំពីស្ដាប់ ;

៣– បញ្ញាកើតអំពីបរិនភាវនា ។

បើបានប្រកបព្រមដោយហេតុទាំង ៣ យ៉ាងនេះ បញ្ញាទើបកើតឡើងគ្រប់គ្រាន់មិនខ្វះខាតឡើយ ។

ឯគ្រឿងប្រកបផ្សំនោះលោកពោលទុកមកមាន ៤ យ៉ាង គឺ:

១ – សេពគប់នឹងលោកដែលប្រព្រឹត្តល្អដោយកាយ - វាចា - ចិត្ត ដែលហៅថា សប្បុរស ;

២ – ស្ដាប់ពាក្យប្រៀនប្រដៅលោកដោយគោរព ;

៣– ធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា ;

៤ – ប្រតិបត្តិធម៌ឲ្យសមគួរដល់ពាក្យប្រៀនប្រដៅរបស់លោក ។

**សេពគប់នឹងសប្បុរស** ការសេពគប់ជាកម្លាំងយ៉ាងធំ បើគប់ពាល ៗ នាំឲ្យទុក្ខ គប់សប្បុរសជាហេតុនាំឲ្យកើតផលកើតប្រយោជន៍ក្នុងលោកនេះនិងលោកខាងមុខ, ព្រោះលោកប្រុនប្រសប់ណែនាំប្រៀនប្រដៅបុគ្គលដែលចូលទៅគប់ប្រសព្វនឹងលោកនោះ ឲ្យយល់ច្បាស់ទាំងផ្លូវលោកនិងផ្លូវធម៌ ឲ្យមានស្មារតីនឹករឭកទូវធម៌ដែលខ្លួនគួរប្រព្រឹត្ត និងមិនគួរប្រព្រឹត្តផង, ឲ្យមានប្រាជ្ញាចេះពិចារណាវែកញែកឲ្យស្គាល់បាបបុណ្យគុណទោសផង, ហើយក៏តាំងចិត្តស្តាប់ឱវាទលោកដោយសេចក្តីគោរព · មិនបណ្តែតបណ្តោយចិត្តឲ្យរសាត់ទៅក្នុងអារម្មណ៍ផ្សេង ៗ ដំកល់ចិត្តឲ្យមាំក្នុងឱវាទរបស់លោកនោះៗ, លុះស្តាប់បានហើយក៏ធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា. ហើយក៏ពិចារណាឲ្យស្គាល់ន័យនិងគុណធម៌នោះៗ និងវែកញែកទៅតាមទំនងធម៌ថា: ធម៌នេះគួរប្រតិបត្តិ, ធម៌នេះមិនគួរប្រតិបត្តិ, ហើយជ្រើសរើសប្រតិបត្តិឲ្យសមគួរទៅតាមកាលនិងតាមប្រទេសនិងភូមិស្ថានរបស់ខ្លួន និងប្រតិបត្តិឲ្យត្រូវតាមសំនួនរបស់ធម៌មិនឲ្យខុសអំពីគំរិតរបស់ធម៌ឡើយ ។

ម្យ៉ាងទៀតលោកពន្យល់ថា: បណ្តាមនុស្សដែលកើតមកក្នុងលោកនេះ បើទុកណាជាមានកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា ជាគ្រឿងជំនួយជួយក្នុងកិច្ចការរកស៊ីចិញ្ចឹមជីវិតអំពីដើមខ្លះក៏ពិតមែនហើយ ប៉ុន្តែ

នឹងធ្វើការងារនោះៗ ឲ្យសម្រេចដោយងាយ ហើយស្រួលបួលមិនឲ្យខុសខូចខាត នឹងប្រព្រឹត្តខ្លួនឲ្យតាំងនៅក្នុងសេចក្តីល្អ ដែលជាហេតុនាំឲ្យបានសេចក្តីសុខ-ចំរើននោះ ក៏ត្រូវតែអាស្រ័យសេចក្តីចៀវឆ្លាសវាងវៃស្ទាត់ជំនាញ, ហើយត្រូវជាមនុស្សចេះសង្កេតរកហេតុផល ព្រមទាំងធ្លាប់បានជួបប្រទះឃើញបែបផែន នឹងប្រវេណីដែលមានមកអំពីដើមផង, ទើបការងារដែលនឹងប្រព្រឹត្តនោះបានសម្រេចដោយស្រួលបួលឆាប់រហ័សរួសរាន់ទាន់ចិត្តប្រាថ្នា ។

ឯសេចក្តីចៀវឆ្លាសវាងវៃស្ទាត់ជំនាញក្នុងការងារ ព្រមទាំងកិរិយាមារយាទនឹងប្រាជ្ញាជាគ្រឿងសង្កេតរកហេតុរកផល ដែលនឹងកើតឡើងបាននោះ ក៏មកតែអំពីចូលទៅជិតគប់ប្រសព្វនឹងសប្បុរសប៉ុណ្ណោះ ព្រោះហេតុដូច្នោះ សាធុសប្បុរសទាំងឡាយគួរគប់ប្រសព្វនឹងសប្បុរសនេះតែម្យ៉ាង ព្រោះលោកអាចនាំឲ្យចំរើនប្រាជ្ញា ។

**ការស្តាប់ពាក្យប្រៀនប្រដៅលោកដោយគោរព** នោះសេចក្តីអធិប្បាយថា: បុគ្គលគប្បីសង្រួមប្រយ័ត្នចិត្តកុំឲ្យរាយមាយ ឬកំចាត់បង់នូវចិត្តរវើរវាយរសាប់រសល់កុំឲ្យមាននៅក្នុងសន្តានបាន, ដំកល់ចិត្តឲ្យនឹងនួនប្រុងចាំស្តាប់ពាក្យឱវាទរបស់លោកជាសប្បុរស ដើម្បីឲ្យបានសម្រេចសម្បត្តិជាលោកិយនឹងលោកុត្តរណាមួយ, ឬដើម្បីឲ្យបានចេះចាំច្រើនជាពហុស្សុតឡើង ហើយនឹងសំដែងប្រាប់ដល់អ្នកដទៃដោយសេចក្តី

អនុគ្រោះ ឲ្យអ្នកដទៃបានធ្វើការកុសលគ្រាន់ជាឧបនិស្ស័យទៅអនាគត ។ ម្យ៉ាងទៀត សូម្បីទុកជាដែលលោកទូន្មានប្រៀនប្រដៅឲ្យខំប្រឹងប្រែងរកស៊ីចិញ្ចឹមជីវិត ទឹងធ្វើការងារផ្សេងៗ ដទៃដែលជារបស់ឥតទោស ឬឲ្យខំរៀនសូត្រចំណេះវិជ្ជាដែលឥតទោស ក៏ត្រូវកុំប្រហែសធ្វេសក្នុងការស្ដាប់ឲ្យសោះ ព្រោះការតាំងចិត្តស្ដាប់មាំជាគ្រឿងចំរើនប្រាជ្ញា ។

**ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា** នោះ ហៅឲ្យខ្លីថា យោនិសោមនសិការៈ គឺកិរិយាត្រិះរិះពិចារណាឲ្យស្គាល់ហេតុនិងផលអាក្រក់ ល្អ ដោយយោបល់ដ៏ប្រពៃ; អធិប្បាយថា: បណ្ដាកិច្ចការគ្រប់ចំពូក ដែលបុគ្គលធ្វើរួចហើយក្ដី កំពុងធ្វើក្ដី, ប្រុងនឹងធ្វើក្ដី, ក៏ត្រូវតែអាស្រ័យយោនិសោមនសិការៈជាមុនដកប ទើបការងារទាំងនោះសម្រេចទៅបានដោយស្រួលមិនខ្ទាំខ្ទង់ឡើយ ; ឯយោនិសោមនសិការៈនោះមិនមែនជាតួបញ្ញាទេ គ្រាន់តែជាឧបាយជួយឧបត្ថម្ភឲ្យមានប្រាជ្ញាឆ្លៀវឆ្លាសកាន់តែវៃស្ទាត់ជំនាញក្នុងការងារនោះៗ ប៉ុណ្ណោះឯង ; ព្រោះមនុស្សយើង បើកាលណាមានដំណើរទៅកាន់ទីដទៃៗ ហើយបានជួបប្រទះនឹងវត្ថុអ្វីៗ ឬវិធីបែបផែនដែលគេតាំងទុកក្នុងទីណាមួយ ឬបានរៀនចំណេះវិជ្ជាណាមួយ, បើមិនខំប្រឹងប្រែងយកចិត្តទុកដាក់ពិចារណាត្រិះរិះដោយយោបល់ ឲ្យស្គាល់ហេតុផលក្នុងវត្ថុ ឬវិជ្ជានោះៗ ឲ្យសព្វគ្រប់ទេ ការដែលឆ្លៀវឆ្លាសកាន់តែវៃក្នុងកិច្ចការនោះៗ ក៏មិនបានកើតឡើង ;

ឯយោនិសោមនសិការៈនេះ សុំសេចក្ដីបាននាំងផ្លូវលោកនឹងផ្លូវធម៌ ។ ឯចំណេះវិជ្ជាផ្លូវលោកនោះ គឺត្រូវរៀនឲ្យចេះអក្សរនឹងលេខនព្វន្តគុណហារជាដើម, ឯវិជ្ជាខាងផ្លូវធម៌ គឺត្រូវរៀនឲ្យចេះព្រះបរិយត្តិធម៌ជាដើម, កាលបើបានរៀនសូត្រវិជ្ជាណាមួយហើយ ក៏ត្រូវតែប្រើគំនិតពិនិត្យពិចារណាឲ្យចេះចាំស្ទាត់ប្រាកដក្នុងចិត្ត ឬបានមើលក្បួនតម្រាដែលអ្នកប្រាជ្ញបានរចនាជាវិធីបែបផែនទុកមក ដូចជាសម័យសព្វថ្ងៃនេះ ត្រូវតែកត់គូសចំណាំទុកក្នុងចិត្ត នូវសេចក្ដីត្រង់ណាដែលវៀកវៃ្កកវៀកគំនិត ត្រូវសង្កេតមើលឲ្យឃើញហេតុផល ហើយគិតស្រាវជ្រាវការកឲ្យទាល់តែចូលចិត្តសេចក្ដីនោះសិមឈប់, យ៉ាងនេះឯង វិជ្ជាដែលរៀននោះទើបនឹងក្ជាប់ស្ទាងរុងរឿងឡើងជាលំដាប់ៗតទៅ ។ បើនិយាយខាងផ្លូវធម៌វិញ គឺកាលដែលបានជួបប្រទះវត្ថុអ្វីជារបស់មានវិញ្ញាណ ឬឥតវិញ្ញាណ ក៏ត្រូវតែមានគំនិតត្រិះរិះពិចារណាឲ្យឃើញច្បាស់ថាជារបស់មិនទៀងជាទុក្ខ មិនមែនខ្លួនប្រាណ, យ៉ាងនេះទើបប្រាជ្ញាជាន់ខ្ពស់ដែលលោកកប់បញ្ញាលទៅក្នុងលោកុត្តរបញ្ញានេះកើតឡើងបាន ; ហេតុដូច្នោះសាធុសប្បុរសគួរតែបង្កើតយោនិសោមនសិការៈឲ្យមាននៅក្នុងខន្ធសន្តាន, ព្រោះជាធម៌សំខាន់ខាងធ្វើឲ្យចំរើនប្រាជ្ញា ។

**ប្រតិបត្តិនូវធម៌សមគួរដល់ធម៌** - គុណធម៌នេះជាប់មកពីយោនិសោមនសិការៈ; ព្រោះថាបុគ្គលកាលនឹងប្រតិបត្តិធម៌នោះ លុះតែបានត្រិះរិះពិចារណាឲ្យស្គាល់ហេតុផលសភាវធម៌នោះៗជាមុនសិន ទើប

នឹងប្រតិបត្តិឲ្យសមគួរដល់គំរិតធម៌នោះៗ បាន, កាលបើបុគ្គលប្រតិបត្តិឲ្យត្រឹមត្រូវតាមគំរិតរបស់ធម៌ហើយ រមែងបានជួបប្រទះនឹងសេចក្ដីសុខសេចក្ដីចំរើនមិនខានឡើយ ។

ចំណែកបុគ្គលដែលប្រព្រឹត្តធម៌ ប៉ុន្តែមិនបានជួបប្រទះនឹងសេចក្ដីសុខៈជាយបរិបូណ៌ ដោយហេតុបុគ្គលនោះឯងប្រតិបត្តិធម៌មិនសមគួរដល់ធម៌ដែលខ្លួនបានត្រិះរិះឃើញ ព្រោះបុគ្គលខ្លះប្រឹងប្រតិបត្តិធម៌តឹងហួស ខ្លះប្រតិបត្តិធម៌ធូរហួសពេក; ព្រោះតែតឹងហួសធូរហួសយ៉ាងនេះ បានជាមិនបានជួបប្រទះនឹងសេចក្ដីសុខសេចក្ដីចំរើន ដែលជាផលនៃការប្រតិបត្តិនោះៗ ដោយគ្រប់គ្រាន់ឡើយ ។ ឯការដែលប្រតិបត្តិធម៌សមគួរដល់គំរិតរបស់ធម៌នោះ គួរយ៉ាងដូចជាបុគ្គលដែលរក្សាសីល គប្បីសង្រួមប្រយ័ត្នរាំងសិក្ខាបទដែលខ្លួនបានកាន់កាប់ហើយ កុំឲ្យធ្លុះធ្លាយប្លុះសៅហ្មងសិក្ខាបទណាមួយ ដំណាលនោះ អ្នកប្រតិបត្តិនឹងកើតសេចក្ដីត្រជាក់ចិត្តឥតក្ដៅក្រហាយ ។ ឯការប្រតិបត្តិធម៌សមគួរដល់ធម៌ ដូចសំដែងមកនេះ រមែងបានសេចក្ដីសុខ ទាំងក្នុងជាតិនេះនឹងជាតិខាងមុខ ហើយនឹងបានជាបច្ច័យនៃព្រះនិព្វានជាអវសានជាតិមិនឃ្លាតឡើយ ។

កាលបើសាធុសប្បុរសមានសេចក្ដីប៉ុនប៉ងចង់បានប្រាជ្ញា គួរខំបណ្ដុះដាំផ្សាំប្រាជ្ញាឲ្យកើតឡើង ត្រូវប្រកបផ្សំធម៌ទាំង ៤ នេះឲ្យកើតមានក្នុងសន្ដាន ទើបប្រាជ្ញាកើតចំរើនឡើងជាលំដាប់ ។

**សំដែងមកអំពីធម៌ជាគ្រឿងចំរើនប្រាជ្ញាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។**

សារលិខិត

# លោកស្វាមី វិវេកានន្ទ

Message de Swami Vivekananda

ដកស្រង់ពីទស្សនាវដ្ដី ហ្វ្រង់អាស៊ី ថ្ងៃ ១៩ វិច្ឆិកា ១៩៤៦

## លោកប៉ាយ-ប៊ុកក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែប្រួល

(តចប់)

---

ដែលយើងត្រូវការក្នុងសម័យបច្ចុប្បន្នជាងគេទាំងអស់ ខានមិនបាន គឺយើងដឹងថា មានអាទិទេពមួយ (un Dieu) ហើយយើងអាចយល់ឃើញបាននូវអាទិទេពនោះស្ថិតនៅពាសពេញទាំងអស់ឥតមានកំណត់ ។

ទឹកមួយដំណក់នៅក្នុងសាគរ, ស្លឹកឈើនៅក្នុងព្រៃព្រឹក្សា, ដុំមួយចំណិតមិនអាចមាននៅក្នុងគេហដ្ឋាននៃអាទិទេព ដែលមានភោគទ្រព្យ (សេដ្ឋី) ទេ ប៉ើព្រោះអង្គមិនមានព្រះទ័យមេត្តាករុណាដល់សត្វសត្វ ។ តាមន័យផ្ទុយគ្នាវិញ, បើមានធនូៈមាំ, ទន្លេទាំងប៉ុន្មានអាចកើតមានឡើងបាននៅពេលខ្យាច់រហោស្ថាន, ហើយពួកសម្បុរយាចកទៅជាមានភោគទ្រព្យទៅវិញ ។

តើការដែលពោលនេះគ្រាន់តែជាទេវតាមានខ្ញុំសារឬជាជីវភាពពិតប្រាកដមែន? ។

ជីវិតមានសភាពខ្ពង់ហើយលោកដែលប្រកបដោយអនត្តាធម៌ ក៏ជាវត្ថុមិនបានស្ថិតស្ថេរចិរកាល តែអ្នកណាដែលមានជីវិតរស់នៅ ដើម្បីប្រយោជន៍ញាតិមិត្ត អ្នកនោះគេហៅថារស់នៅដោយថ្លៃថ្លា ; ចំណែកអ្នកដែលគ្មានធ្វើប្រយោជន៍ដល់ញាតិមិត្ត ទុកដូចជាស្លាប់ ។

ពួកបព្វាទស្ស៍ "អ្នកឃើញនូវកាលជាអនាគត" (Prophète) មិនមែនមានសភាពដូចគ្នាកង់ការមើលឃើញនូវអនាគតនោះដោយបញ្ញាចក្ខុទេ ។ គឺជាមនុស្សមានលក្ខណៈដូចអ្នកទាំងខ្ញុំ, តែពួកបព្វាទស្ស៍ជាពួកយោគាវចរយ៉ាងចំណានហើយលោកបានហាត់ឈានចិត្ត ដែលអ្នកទាំងខ្ញុំអាចធ្វើបានដូចគ្នា ។ ការដែលបុគ្គលម្នាក់ហ្វឹកហាត់ចិត្តទៅដល់ថ្នាក់ឈានជាពស្តុតាងបញ្ជាក់ឲ្យឃើញជាក់ស្តែងថា មនុស្សឯទៀតក្រៅពីព្រះយោគាវចរនេះ ក៏អាចព្យាយាមហាត់ចិត្តឲ្យដល់ថ្នាក់នោះបានដូចគ្នា ។ កង្វៀងនេះ មិនត្រូវពោលតែត្រឹមសំដីប៉ុណ្ណោះទេ បុគ្គលទីមួយ ៗ ត្រូវប្រឹងប្រែងហ្វឹកហាត់ចិត្តឲ្យបានដល់ថ្នាក់នោះផងទើបប្រសើរ នេះហើយដែលគេហៅថាសាសនា ។

ករណីយកិច្ចតែមួយហើយពិត គឺការញ៉ាំងខ្លួនឲ្យមានសេរីភាពឡើង, ហើយធ្វើការដូចជាសញ្ញាសត្វសេរី ។ ត្រូវបំពេញការងារដោយអធិដ្ឋានការនោះចំពោះអាទិទេព ។ ព្រោះករណីយកិច្ចទាំងអស់នោះត្រូវធ្វើដើម្បីទីងដោះបំណុលដែលជំពាក់អាទិទេព ។

គ្មានការណាដែលមានន័យត្រឹមតែរកវត្ថុធាតុទេ ។ ការទាំងអស់សុទ្ធតែអភិវឌ្ឍន៍ ហើយជាការផ្គងចិត្តចំពោះអាទិទេពទាំងអស់ ។

ដល់ខ្លួនខ្ញុំកាន់តែទោរទន់ចាស់ដក, ខ្ញុំដឹងថា ខ្ញុំបានស្វែងរកកិត្តិយសក្នុងវត្ថុបគាចទៅវិញ ។ មិនថាអ្នកណាទេ ដែលគេអាចធ្វើឲ្យកិត្តិនាមល្បីល្បាញបានដោយសារមានឋានន្តរៈសំខាន់ក្នុងលោក ។ សូម្បីតែអ្នកខ្លាចក៏អាចអប់រំចិត្តឲ្យទៅជាអ្នកក្លាហានបាន ដោយការផ្គងចិត្តទៅរកស្ថិតណាដែលគេរៀបជាផ្លូវហែពីខាងមុខធាកកេងល្ងោន ។ ព្រោះប្រជាជនទាំងអស់ដែលទៅទស្សនា តែងក្រឡេកមើលទៅចំអ្នករបាំនោះ ។ ខ្ញុំកាន់តែយល់បន្តិចម្តងៗថា កិត្តិយសដ៏ប្រសើរនោះ, បើគិតដោយស្មានគឺជាកិត្តិយសនៃដង្ករ ដែលបំពេញករណីយកិច្ចរបស់ក ដោយសារចិត្តនឹងនួន ព្រមទាំងសេចក្តីព្យាយាមពីពេលមួយទៅពេលមួយ, ពីម៉ោងមួយទៅម៉ោងមួយ ។

យើងចង់បានទាំងអស់ វៀរលែងតែអាទិទេព ហើយបានជាបំណងដូចនោះ ព្រោះសេចក្តីប្រាថ្នានៃមនុស្សសាមញ្ញជាប់ស្អិតទៅនឹងពាហិរលោក ។ ដរាបណាសេចក្តីត្រូវការរបស់យើងនៅស្អិតត្រង់ព្រំដែននៃលោកធាតុ, ដរាបនោះ យើងមិនមានបំណងត្រូវការនឹងអាទិទេពឡើយ ។ លុះត្រាតែជីវភាពរបស់យើងទៅជួបប្រទះនឹងជោគវាសនាអាក្រក់ ព្រមទាំងសេចក្តីលំបាកទុក្ខព្រួយសព្វគ្រប់, ទើបយើងប្រាថ្នារកវត្ថុដ៏ឧត្តម ក្នុងពេលនោះយើងទើបបែរវិលត្រឡប់ទៅរកអាទិទេពវិញ ។

ជីវភាពគឺការបណ្ដោយសត្វលោកឲ្យទៅតស៊ូដោយសេរី ចំពោះទេសៈកាលៈ ដែលមានបំណងនឹងធ្វើជីវិតឲ្យសាបសូន្យ ជាហេតុឲ្យកើតនូវវិវឌ្ឍនធម៌ ។

សេចក្ដីខ្លាចមិនត្រូវឲ្យមានក្នុងសន្ដានឡើយ ។ សភាពសម្បយាបកក៏មិនត្រូវឲ្យមានដែរ ។ តែត្រូវសូមបំណងទៅកាន់អារ្យធម៌ ។ អ្នកណាដែលជាឧបាសកឧបាសិកានៃមាតាធម៌ (ធម៌ដោយសុក្រិតភាព). មានចិត្តធ្ងន់ធ្ងប្រហែលនឹងថ្មពេជ្រ ហើយគ្មានខ្លាចតក់ស្លុតដូចសត្វសិង្ហឡើយ ។ បើទុកជាចក្រវាឡទាំងមូលរលំរលាយទៅជាបរមាណូធ្លាក់មកជិតជើង, ក៏សេចក្ដីក្លាហាននៃអ្នកនោះ តែងស្ថិតស្ថេរចិរកាលជានិច្ចឥតមានប្រែប្រួល ។ អ្នកត្រូវបំពេញករណីយកិច្ចធ្វើឲ្យមាតាធម៌ទ្រង់ព្រះសណ្ដាប់អ្នក តែកុំឲ្យឱនលំទោនពេក ។ ត្រូវឲ្យអ្នកជ្រាបថា: មាតាធម៌ជាអនន្តពល (Toute Puissance) អាចធ្វើឲ្យថ្មសិលាទៅជាវីរបុរសបាន ។

អាត្មនជាអនន្តពល ព្រោះមានលក្ខណៈដូចអាទិទេព ។ វត្ថុបំណងគឺធ្វើបាតុកម្មបញ្ចេញនូវអាទិទេវគតិ (Divinité) ពីខាងក្នុង ដោយត្រួតត្រាចំពោះខ្លួនដោយខ្លួនឯង ទាំងធម្មជាតិខាងក្នុងខាងក្រៅ ។ ឲ្យអ្នកព្យាយាមដោយធ្វើកិច្ចការផ្សេងៗ ឬដោយស្វែងរកធម៌ ឬដោយការចំរើននៃចិត្ត ឬដោយទស្សនវិជ្ជា ឬដោយមធ្យោបាយតែមួយ ឬរួបរួមទាំងអស់ដូចពណ៌នាខាងលើហើយ ត្រូវអ្នកប្រតិបត្តិការនេះដោយសេរី ។ ត្រង់នេះ

ហើយដែលហៅថាសាសនាដោយសុក្រិតភាព ។ លទ្ធិឡាក់គោលសាសនា, ទំនៀមទម្លាប់, សៀវភៅ, វត្តអារាម និងទម្រង់ផ្សេងៗនេះ ជាវត្ថុមិនសូវមានសារៈសំខាន់ប៉ុន្មានទេ រាប់ចុះមកថ្នាក់ទីពីរ ។

អាត្ម័នជាភាព ហើយភាពទាំងអស់ស្ថិតនៅលើនភាល័យ ដែលមានសភាពជាអនន្តមាត្រា (infini) ។ នៃមហាមេឃជាលក្ខណៈនៃអាទិ-ទេពជាម្ចាស់ ។ នេះហើយជាឫសសច្ចធម៌, ធម៌ពិតដែលស្ថិតនៅក្នុងបុគ្គលនីមួយៗ គ្រប់រូបទាំងអស់, សាសនាបានស្វែងរកជាបឋមនូវភាពខ្វះក្នុងចំណោមភាពជាច្រើន ដែលរះម្ខាងជើងមេឃ ហើយបានបំពេញអវសានកិច្ចបង្ហើយ ដោយបានរកឃើញនូវភាពនោះទាំងអស់ ព្រមទាំងខ្លួនយើងរលាយចូលទៅនឹងអាទិទេព ។

ចប់

## ល្ងង់ឃើញជិត ប្រាជ្ញពិតឃើញឆ្ងាយ

ឆ្កែចចកនឹងពពែ បានចុះកិច្ចសញ្ញាសន្តិភាពជាមួយគ្នា តែឆ្កែចចកតម្រូវឲ្យពពែដេញឆ្កែស្រុកចេញ; លុះអំណើះខាងក្រោយមក ពពែក៏ទៅជាចំណីចចក ដោយហេតុគ្មានឆ្កែការពារ ។

យ. អ.

## ការបណ្ដុះនិស្ស័យ

# ព្រះមហាឧត្ដមវិជ្ជា ផលញ្ញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីវត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌិតរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ ពិនិត្យកែ

(តទៅ)

---

គ) កុំអង្គុយឬឈរនៅបង្កាន់ដៃស្ពាន កុំអង្គុយឬឈរឬក៏ដេកនៅកណ្ដាលផ្លូវ កុំអង្គុយគងអន្ទាក់ខ្នង ឬលើកជើងឡើងដាក់លើកន្ទេងអង្គុយ ឬកន្ទេងដេក ក្នុងពេលដែលជិះយានពាហនៈ ដូចជារថយន្ត រថភ្លើងជាដើមឡើយ ព្រោះជាទីនាំឲ្យទើសទែងដល់អ្នកដែលដើរទៅមកនឹងជាទីចង្អៀត ឬប្រឡាក់សំលៀកបំពាក់ របស់អ្នកដែលជិះជាមួយ ។

ឃ) កុំប្រើកំឡាំងប្រៀតប្រៀនប្រជ្រៀតយកតែឈ្នះនៅក្នុងទីប្រជុំជន ដូចជាក្នុងការជិះយានពាហនៈ ការចូលទិញមូលប័ត្រ ចេញចូលតាមទ្វារជាដើម ឬចូលតាមទ្វារតាមច្រកល្ហកនៅក្នុងទីណាមួយ, បើគ្មានហេតុដ៏សមគួរទេ កុំបោមពេមអ្នកដទៃ នាំឲ្យគេទើសទែងកើតសេចក្ដីរំខានចិត្ត, កុំគូស-សរសេរឬបិទសំបុត្រ ឬក៏ដាក់របស់គួរខ្ពើមក្នុងទីមិនគួរធ្វើ, កុំបោលសម្រាមទឹកវត្ថុសោកគ្រោក ក្នុងទីមិនគួរបោល ព្រោះជាហេតុនាំឲ្យកើតបដិកូលដល់សាធារណជន ។

៥) ចូរគោរព ចូរអើពើ ចូរទទួល អ្នកដែលមកជាមួយ ដោយមារយាទដ៏សុភាពពបសា ចូរធ្វើទឹកមុខឱ្យយ៉ាងរីករាយស្រស់ស្រាយ ចូរប្រតិបត្តិចំពោះគ្នាដោយសេចក្ដីស្មោះត្រង់ ចូរធ្វើឱ្យគ្នាសប្បាយចិត្តប្រតិបត្តិតាមបំណងរបស់គ្នាដោយល្អ ចូរប្រតិបត្តិខ្លួនកុំឱ្យជាទីរង្កៀសដល់គ្នា ដូចយ៉ាង កុំដក់ប៉ារី កុំបរិភោគគ្រឿងស្រវឹង (ចំពោះកាលដែលមិនសមគួរ) កុំខ្សឹបខ្សៀវ កុំខាកស្ដោះដាដើម ឬក៏ធ្វើអ្វីៗដទៃទៀតដែលមិនសមគួរចំពោះមុខគេទៀត ។

**២ – អ្នកល្អតែងមានចិត្តល្អ** – អ្នកល្អតែងប្រកាន់ថា: "មនុស្សលោកនេះ បើមិនមានអ្នកចិត្តល្អហើយ ក៏ក្លាយទៅជាកពនៃអសុរកាយដែលពេញពោរទៅដោយការទុរយស មុខគួរឱ្យខ្លាចក្រៃលែង គឺចេះតែមានមាយាសាថេយ្យ មានចិត្តឫស្យាឈ្នានិសចំពោះសេចក្ដីល្អរបស់គ្នានឹងគ្នា" ហើយប្រកាន់ថា: "អ្នកមានចិត្តល្អតែងតែណនាំតែកងផ្លូវដ៏ល្អដែលជាហេតុឱ្យកើតសេចក្ដីកក់ក្ដៅដល់គ្នានឹងគ្នា មិនរើសថាក្នុងករណីយណាៗឡើយ" ។ អស់លោកទាំងឡាយ ចូរជាអ្នកមានចិត្តល្អ ប្រកបដោយមេត្តាករុណា គិតដល់ប្រយោជន៍របស់ពួកគណៈឱ្យបានច្រើនជាងប្រយោជន៍របស់បុគ្គលម្នាក់ឬរបស់ខ្លួនឯង រក្សាប្រយោជន៍របស់សាធារណជនទុក បេះពិចារណាឃើញទ្រព្យរបស់អ្នកដទៃ ដូចជាមនុស្សដែលមានកំលាំងខ្សោយជាងមនុស្សដែលនៅក្នុងការពិទ័ក្ខ មនុស្សដែល

ស្មើគ្នាឬខ្ពស់ជាងខ្លួន ចូរគោរពចំពោះអ្នកដែលគួរគោរព កុំធ្វើចិត្តអាក្រក់ចិត្តទៅ ចូរជួយទុក្ខភ័យចំពោះអ្នកដែលគួរជួយ ចេះបន្ធូរបន្ថយ ចេះសម្រាលទុក្ខរបស់អ្នកដែលមានទុក្ខធំ ឬក៏ក្រីក្រ ដែលគ្មានមិនមានឱកាសទីពឹងផ្សាយសេចក្តីល្អបានដូចយើង, ដោយហោចទៅ សូម្បីតែពួកសត្វតិរច្ឆាន ក៏យើងត្រូវមានសេចក្តីមេត្តាករុណាប្រណីដែរ ។

ការអួតកំលាំង អួតអំណាច អួតទ្រព្យសម្បត្តិ ឬសមត្ថភាព ដើម្បីកៀរគេយករបស់អ្នកដទៃមកធ្វើជារបស់ខ្លួន អ្នកល្អមិននិយមសោះឡើយ ព្រោះឃើញថា "ការអួតហ៊ានជាសម្បត្តិរបស់អ្នកខ្លាច ការអួតឈ្លាសវៃជាសម្បត្តិរបស់អ្នកល្ងង់ ការអួតមានជាសម្បត្តិអ្នកក្រ" ។ ប៉ុន្តែប្រកាន់តាមគតិថា "ត្រូវមានកំលាំងដូចយក្ស តែមិនត្រូវប្រើកំលាំងកាយយ៉ាងយក្សឡើយ" ។ អ្នកល្អតែងរាប់អានភាពជាអ្នកមានកំលាំង ទឹងចូលចិត្តប្រើកំលាំងក្នុងផ្លូវដែលត្រូវ ។ ហេតុនេះ បើយើងប្រកាន់ថា ខ្លួនយើងជាមនុស្សល្អហើយកុំគប្បីប្រើកំលាំងកាយ ធ្វើទារុណកម្មចំពោះអ្នកដែលខ្សត់ខ្សោយគតទីពឹង កុំសំដែងកិរិយាទឹងរឹងវា សង្កត់សង្កិនជិះជាន់មើលងាយអ្នកដទៃឡើយ ត្រូវប្រើកំលាំងសម្រាប់ជាគ្រឿងជួយសង្គ្រោះ កៀនកក់ផងគ្នាវិញ ដោយមិនត្រូវរើសថាប្រុសស្រី ក្មេងចាស់ឬជាតិសាសនាណាឡើយ, ក្នុងខណៈដែលគ្នាធ្លាក់ទៅក្នុងសេចក្តីអន្តរាយ ចូរលើកដៃជួយធ្វើកិច្ចគ្នាភ្លាមៗ កុំគិតនឿយហត់ ឬសេចក្តីអន្តរាយណាមួយទាំងអស់ ។

៣ — **អ្នកល្អតែងមានសេចក្ដីស្មោះត្រង់** សេចក្ដីស្មោះត្រង់ ជាដួងពន្លឺរស្មីដ៏ស្វាងរុងរឿងនៅជុំវិញខ្លួន ធ្វើទឹកមុខរបស់ខ្លួនឲ្យស្រស់បំព្រងបាន ។ ការវៀចវេរ នាំឲ្យទឹកមុខស្រអាប់ ហាក់ដូចជាប្រឡាក់ធូលី ។ សេចក្ដីស្មោះត្រង់នេះ ជាគុណធម៌ខាងដើម នឹងខាងចុងនៃវត្តទាំងពួង លោកប្រៀបថា “សេចក្ដីស្មោះត្រង់ប្រហែលគ្នានឹងមាតា ការប្រព្រឹត្តត្រូវធម៌ប្រហែលគ្នានឹងបិតា សេចក្ដីករុណាប្រហែលគ្នានឹងភរិយា ការទន់លំទោនប្រហែលគ្នានឹងបុត្រ, ឯសេចក្ដីអង់អាចប្រហែលគ្នានឹងមិត្ត” ព្រោះបើយើងមានសេចក្ដីស្មោះត្រង់ហើយ សេចក្ដីល្អដទៃៗ ក៏កើតមានឡើងបានផង ប្រសិនបើយើងជាមនុស្សវៀចវេរវិញ គុណធម៌ដទៃៗ ក៏មិនមានឡើងដែរ ។

យើងគង់ធ្លាប់បានឃើញ មនុស្សខ្លះដែលសំដែងកិរិយាសុភាព និយាយពីរោះផ្អែមល្ហែមចំពោះមុខគេ តែលុះគេត្រឡប់ទៅវិញហើយ ក៏បញ្ចេញកិរិយាអាក្រក់ និយាយដើមគេ ពោលពាក្យអាក្រក់ៗឲ្យគេតាមក្រោយ នេះជាមនុស្សមិនស្មោះត្រង់ គឺជាមនុស្សចិត្តវៀចនៅមុខគេ ចេះធ្វើកិរិយាសុភាព និយាយពាក្យពីរោះផ្អែមល្ហែមប្រចុបប្រចែងលើកដំកើងសរសើរ លុះគេទៅបាត់ ក៏ត្រឡប់ជានិន្ទា ក្លែងពោលទោសផ្សេងៗទៅវិញ ចូលគ្នានឹងបទថា “នៅមុខគោរព នៅក្រោយឡក, ចំពោះមុខផ្ទៃទន្ទាប់ កំបាំងមុខផ្ទៃតាកោ” ។ កិរិយារបស់មនុស្ស

អាសត្យ (មនុស្សវៀច) ជាកិរិយាកូតករ ជាកិរិយាក្លែងក្លាយ ជាកិរិយាកុហក ជាកិរិយានាំឲ្យមានពៀរ មានភ័យជុំទិស គ្មានសេចក្ដីសុខឡើយ ។ ពិតមែន អ្នកដែលមានកិរិយាស្វាមីមិនស្មោះត្រង់, អ្នកដែលមានមាតាបិតាជំពាក់បំណុលគេ ទឹងអ្នកដែលមានបុត្រធីតាសន្ដានអាក្រក់, មនុស្សទាំង ៣ ពួកនេះ ឥតដែលបានសេចក្ដីសុខបន្ដិចបន្តួចឡើយ ។

សេចក្ដីស្មោះត្រង់ជាកេរ្តិ៍វិសេសរបស់អ្នកល្អ តែជាថ្នាំពិសដ៏មានពិសយ៉ាងពន្លឹករបស់មនុស្សអាសត្យ ។ ដូច្នេះអ្នកល្អទើបខំរក្សាតែសេចក្ដីស្មោះត្រង់ ប្រព្រឹត្តតែសេចក្ដីសុចរិតពិតៗ ទាំងចំពោះមុខទាំងកំបាំងមុខ ដើម្បីឲ្យជាតិចំរើនឡើងបានដោយងាយ ត្រូវនឹងបទថា "សេចក្ដីស្មោះត្រង់ជាថ្នាំងទទួលខុសត្រូវនឹងជាគុណធម៌ដ៏ប្រសើរ ចារឹកនៅជាប់នឹងទឹកមុខរបស់មនុស្សស្មោះត្រង់" ។

លោក-អ្នកដែលជាមនុស្សល្អ ចូរជាមនុស្សស្មោះត្រង់ កុំចង់សប្បាយ ចង់សើចលេងហើយពោលកុហកបញ្ឆោតគ្នាឡើយ ចូរកុំវៀចវេរឆបោក បញ្ឆោតប្រវ័ញ្ចន៍ លបលួចរបស់គេដោយសំឡឹងឃើញលាភសក្ការៈ កុំជាមនុស្សប្រើមាយាក្នុងផ្លូវអួតអាងថាខ្លួនជាអ្នកធំ ទឹងកុំក្រឡះពាក្យសន្យា ដែលខ្លួនបានធ្វើជាមួយអ្នកដទៃរួចហើយ សូម្បីអ្នកនោះជាមនុស្សបែបណាក៏ដោយ, ត្រូវរក្សាពាក្យសន្យាទុក ដើម្បីរក្សា

មិត្រសំឡាញ់និងប្រទេសជាតិ តែត្រូវកុំទទួលពាក្យសន្យាកិច្ចដែលលើសវិស័យនិងសមត្ថភាព ឬដែលមិនគួរនឹងធ្វើបាន ; មុននឹងទទួលសន្យាអំពីអ្នកណា ចូរត្រិះរិះឲ្យសព្វគ្រប់សិន លុះបានធ្វើពាក្យសន្យានឹងគ្នាហើយចូរកាន់ពាក្យសន្យានោះ ឲ្យជាប់លាប់ដូចជាទំនៀមទំលាប់ដែលត្រូវប្រព្រឹត្តតាម កុំក្លែងទំលាក់កំហុសលើគេ កុំទទួលធុរៈកិច្ចការដែលខ្លួនមិនអាចធ្វើបាន តែត្រូវប្រុងប្រយ័ត្នរក្សាពាក្យសំដី ប្រតិបត្តិតាមពាក្យសន្យាឲ្យត្រឹមត្រូវ ។

**៤ – អ្នកល្អតែងមានសេចក្ដីសុចរិត** – ការប្រព្រឹត្តល្អបរិសុទ្ធិ ប្រាសចាកមន្ទិលទោសទាំងផ្លូវកាយផ្លូវវាចានិងផ្លូវចិត្ត ហៅថាសេចក្ដីសុចរិត, ដោយចំពោះសំដៅយកសុចរិតកិច្ចមុខក្រសួង សុចរិតកិច្ចការងារ និងសុចរិតកិច្ចការរក្សាវាចា ។ អ្នកល្អរមែងសុចរិតកិច្ចមុខក្រសួង ដូចជារក្សាមុខក្រសួងដោយសុចរិត មិនវៀចវេរឆបោកកស្រ្ដបន្លំយករបស់រាជការ ដោយរត់គយរត់ពន្ធជាដើម, បើខ្លួនជាអ្នកតូចក៏គោរពកោតក្រែងអ្នកធំ បើជាអ្នកធំ ក៏មិនប្រព្រឹត្តរំលោភឬសង្កត់សង្កិនអ្នកតូច ។ ឯសុចរិតកិច្ចការងារ ដូចជាធ្វើការងារដោយសុចរិត មិនធ្វើឲ្យខុសសីលធម៌និងច្បាប់ទំលាប់ ។ សុចរិតកិច្ចការរក្សាវាចា គឺបើខ្លួនជាអ្នកតូច ក៏ស្ដាប់បង្គាប់អ្នកធំ បើជាអ្នកនៅក្រោមសេចក្ដីបង្គាប់បញ្ជារបស់គេ ក៏ស្ដាប់ពាក្យបង្គាប់របស់អ្នកដែលបង្គាប់បញ្ជានោះ ហាក់ដូចជា

ពាក្យបង្គាប់នោះចេញទៅអំពីខ្លួនឯង ឬក៏រក្សាពាក្យសន្យាដែលខ្លួនបាន ធ្វើនឹងអ្នកណាមួយដោយភ្ជាប់ខ្លួន ។ បើជាអ្នកធំវិញ ក៏ត្រូវរក្សាវាចា របស់ខ្លួនឲ្យត្រឹមត្រូវទៅតាមច្បាប់ និងត្រូវប្រើវាចានោះឲ្យហ្មត់ចត់ថ្លៃ ថ្នូរ ហើយទន់ភ្លន់ផ្អែមល្ហែមសុភាពរាបសាផង ដើម្បីឲ្យអ្នកតូចធ្វើតាមបាន ដោយងាយ ។

អស់លោកដែលជាអ្នកល្អ ត្រូវសុចរិតចំពោះមុខក្រសួង កុំធ្វើការ ទុច្ចរិតក្នុងមុខក្រសួង ដូចយ៉ាងកុំវៀចវេរ លបលាក់លួចទ្រព្យរបស់ជាតិ ជាដើម, កុំទទួលសំណូក ព្រោះអ្នកទទួលសំណូកជាអ្នកលក់ខ្លួនឯង ឲ្យដល់អ្នកទិញគឺអ្នកដែលសូក, សូម្បីរបស់កំណាន់ បើមានអ្នកណា មួយឲ្យ ដោយប្រាថ្នានឹងធ្វើកិច្ចរបស់គេឲ្យសម្រេច មិនមែនឲ្យដោយមាន ចិត្តស្រឡាញ់ ឬដោយស្និទ្ធស្នាលទេ បើយើងទទួលរបស់កំណាន់ដូច្នេះ ក៏ឈ្មោះថា បណ្ដោយឲ្យខ្សែបន្ទាត់របស់ខ្លួនផ្អៀងទៅខុសប្រក្រតី គឺជា ផ្លូវនាំចូលទៅកាន់អំពើអយុត្តិធម៌ ដូចគ្នានឹងសំណូកដែរ ព្រោះមាន អំណាចទង់ទាញស្នាមនៃខ្សែបន្ទាត់ដែលត្រង់ឬសេចក្ដីយុត្តិធម៌ ឲ្យផ្អៀង ខុសចាកសេចក្ដីទៀងត្រង់បានដូចគ្នា ។ អ្នកល្អមែងប្រកាន់ថា "ការ ទទួលសំណូកនឹងរបស់កំណាន់នេះ ជាអំពើរបស់មនុស្សចិត្តអាក្រក់" ។

ដូច្នេះ យើងត្រូវកុំទទួលសំណូកនឹងរបស់កំណាន់ឬជំនូន ដោយ សំឡឹងលាភផលក្នុងផ្លូវទុច្ចរិតឡើយ ។ យើងមានកិត្តិសព្ទដោយផ្លូវ

ទុច្ចរិត ទប់ទឹងមនុស្សដែលមិនមានកិត្តិសព្ទពុំបានទេ ព្រោះកិត្តិសព្ទនោះនឹងប្រកាសសេចក្ដីអាក្រក់របស់យើង ឲ្យស្អុយខ្ទរខ្ទាយទៅបាន ហើយយើងមិនត្រូវជួយនរណាមួយ ដោយយល់មុខកូនផ្លូវដែលខុសមុខក្រសួងទេ ចូរខំប្រព្រឹត្តឲ្យល្អក្នុងមុខក្រសួងដោយសុចរិត កុំធ្វើការទុច្ចរិតក្នុងក្លាយឲ្យខុសបាកសេចក្ដីពិតនឹងខូចយុត្តិធម៌ឡើយ គឺកុំលំអៀង ព្រោះស្រឡាញ់ស្អប់ ខ្លាចនឹងវង្វេង ដូចជាកាលយើងមាននាទីជាសាក្សីក៏ចូរជាសាក្សីដ៏សុចរិត កុំជាសាក្សីកុហកក្លូតករ ខុសសេចក្ដីពិតដែលបានដឹងបានឃើញ ; បើមាននាទីជាអ្នកពិភាក្សាក្ដី ចូរធ្វើដោយត្រឹមត្រង់ កុំបេះតែដាក់ទោសមនុស្សតាមតែអំណាចរបស់យើង ដែលអាចដាក់បានឡើយ ត្រូវរក្សាសេចក្ដីសុចរិតទុកឲ្យខ្ជាប់ខ្ជួន ត្រូវនឹងភាសិតថា: "អ្នកពិភាក្សាជាមាតាបិតា ចំណែកគូក្ដីទុកជាបុត្រ, បើបុត្រទាស់ទែងគ្នាឯង មាតាបិតាត្រូវប្រៀនប្រដៅនឹងធ្វើទោសទៅតាមសមគួរ ទាំងត្រូវធ្វើទៅដោយសេចក្ដីស្រឡាញ់រាប់អានមេត្តាប្រណីស្មើគ្នាផង ព្រោះមាតាបិតា មិនដែលប្រាថ្នានឹងក្លែងធ្វើទោសបុត្ររបស់ខ្លួនឡើយ" ។ សូម្បីក្នុងផ្នែកការងារក៏គួរធ្វើដោយត្រឹមត្រូវ កុំគិតឆបោកគេ កុំបៀតបៀនគេ ។

ឯក្នុងការរក្សាវាចាវិញ គឺត្រូវរក្សាពាក្យសន្យាយ៉ាងខ្ជាប់ខ្ជួន រួមសេចក្ដីមកថា "អ្នកល្អត្រូវកុំលោភលន់បានឲ្យហួសប្រមាណ ត្រូវកុំធ្វើកុំនិយាយទៅតាមអំណាចទោសៈនឹងកុំគិតខុសជាត្រូវ" ។

**៥ – អ្នកល្អតែងរក្សាកិត្តិយស** – ភាពជាអ្នកមានកិត្តិយសល្បីល្បាញ ព្រោះមនុស្សដទៃសរសើរលើកដំកើងនឹងគោរពរាប់អានកោតក្រែងដែលកើតឡើងដោយសារការប្រព្រឹត្តិត្រឹមត្រូវដោយត្រៃទ្វារ មិនប្រព្រឹត្តិបៀតបៀនខ្លួនឯងនឹងមនុស្សដទៃឲ្យក្ដៅក្រហាយនោះឯង ចាត់ជាកិត្តិយស ។ អ្នកល្អរមែងរក្សាកិត្តិយសរបស់ខ្លួននឹងប្រទេសជាតិ ចេះអៀនខ្មាសក្នុងការខូចបង់កិត្តិយស ដោយគិតឃើញថា "បើប្រព្រឹត្តិឲ្យខូចកិត្តិយសហើយ មុខជាត្រូវគេសើចចំអកឲ្យថាជាមនុស្សមុខក្រាស់, ដែលជាហេតុនាំឲ្យការខូចបង់កិត្តិយសនោះ មានផ្លូវជាប់នៅនឹងខ្លួនមិនចេះរលាយបាត់ ដូចដើមឈើដែលត្រូវគេចោះគល់ឲ្យមានផ្ទៃច្រើន ត្រង់កន្លែងចោះនោះមិនដែលត្រឡប់ល្អដូចដើមវិញបានទេ" ។ អ្នកល្អនោះទុកជាមាននរណានិយាយទោះគោះបោះបោកនឹងធ្វើអាក្រក់ ចំពោះខ្លួនយ៉ាងណាក៏មិនតបតដោយផ្លូវអាក្រក់វិញឡើយ តែងធ្វើសេចក្ដីល្អតែម្យ៉ាងដើម្បីកិត្តិយសចំពោះមុខក្រសួង ។ បើយើងចង់បានកេរ្តិ៍ឈ្មោះ ចូរយើងធ្វើខ្លួនជាឲ្យមនុស្សល្អ ដោយការប្រព្រឹត្តិតាមច្បាប់នៃការរក្សាកិត្តិយសដូចតទៅនេះ :–

កុំឆប្រវ័ញ្ចន៍វៀចវេរ ដូចជា លួច បោកប្រាស លបលាក់ ឬក្លែងក្លាយជាដើម កុំប្រើវិធីយកមុខយកប្រៀបក្នុងពួកគណៈ ឬប្រទេសជាតិ, កុំធ្វើបាបអ្នកដែលមានកម្លាំងអន់ខ្សោយជាងខ្លួននឹងអ្នកដែលមិនមានអាវុធ

ឬអ្នកដែលគ្មានគ្រឿងការពារខ្លួន; កុំលបប្លន់ប្រទូសរ៉ាយមនុស្សពីខាងក្រោយ កុំធ្វើការញុះញង់សៀតសឹកឬរករឿងគេ កុំកន្លងសំបថឬធ្វើឲ្យខុសសន្យា កុំប្រព្រឹត្តទុយ៌សចំពោះភឿនកក្តិឬពួកគណៈឬក៏ជាតិ កុំបង្កការចលាចលដំលោះទាស់ទែងក្នុងពួកគណៈ កុំប្រព្រឹត្តរំលងច្បាប់បង្គាប់ទំនៀមទំលាប់បែបផែននឹងអំណាចនៃការគ្រប់គ្រងស្រុកភូមិ ។

យើងនឹងទៅជាមនុស្សល្អបាន ត្រូវតែវៀរទោសដែលហាមមកនេះ ហើយត្រូវប្រព្រឹត្តតែតាមច្បាប់ដែលល្អ រក្សាកេរ្តិ៍ឈ្មោះទុកដោយហ្មត់ចត់ កុំធ្វើនិយាយគិតឲ្យប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួននឹងមនុស្សដទៃ ត្រូវតាំងនៅក្នុងសេចក្តីស្មោះត្រង់ឲ្យអស់ពីចិត្ត បើធ្វើឬនិយាយទទួលព្រម ឬហាមឃាត់ដូចម្តេច ត្រូវមានសេចក្តីពិតក្នុងចិត្តដូច្នោះ បើពេលនោះមានសភាពសមគួរនឹងនិយាយហើយ សូម្បីពេលនោះនៅក្រោមមួបនៃសេចក្តីភ័យ ក៏យើងធ្វើឬនិយាយទទួលព្រមឬហាមឃាត់បានតាមសេចក្តីពិតក្នុងចិត្តរបស់យើងដែរ កុំចង់បានវត្ថុណាដែលមិនមែនជារបស់ខ្លួនកុំធ្វើអំពើណាដែលថោកទាប ទាំងនេះគឺដើម្បីរក្សាកិត្តិយសរបស់ខ្លួននឹងជាតិ ។

តាមពិត កាលបើយើងខូចកិត្តិយសហើយ មិនងាយនឹងកែឲ្យត្រឡប់ល្អដូចដើមឡើងវិញបានទេ, ទីណាមិនមានសេចក្តីអៀនខ្មាសទីនោះ ក៏មិនមានកិត្តិយស; ដូច្នេះ អ្នកល្អត្រូវចេះអៀនខ្មាស ព្រោះការចេះអៀនខ្មាសជាឫសគល់នៃសេចក្តីល្អនឹងលក្ខណៈដែលល្អ ព្រមទាំង

ធម្មចរិយាទាំងពួង, ការធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ ព្រោះមិនអៀនខ្មាសនោះ ប្រៀបដូចដើមឈើដែលត្រូវគេបោះគល់ឲ្យផ្ទៃកាន់ដូច្នោះ ។

**៦ – អ្នកល្អតែងស្រឡាញ់សេចក្ដីស្ងប់** សេចក្ដីស្ងប់នៅត្រង់ចិត្តដែលលះអត់ធន់ មិនមែននៅត្រង់ការអត់សង្កត់ចិត្តទេ ។ បើចិត្តលះអត់ធន់មិនធ្វើសេចក្ដីអាក្រក់ហើយ កិរិយានឹងពោលស្ងប់តាម ព្រមទាំងលះបង់អំពើអាក្រក់នឹងការនិយាយអាក្រក់ចេញបានទាំងអស់ ។ ការលែងធ្វើអាក្រក់ លែងនិយាយអាក្រក់នោះហៅជាសេចក្ដីស្ងប់ ។ សេចក្ដីស្ងប់នេះជាផលនៃការតាំងនៅក្នុងធម៌, សេចក្ដីសុខជាផលនៃការធ្វើកាយ វាចា ចិត្ត ឲ្យស្ងប់, សេចក្ដីឆ្អែតចិត្ត ជាផលនៃការមានសេចក្ដីសុខ ។ អ្នកមិនប្រព្រឹត្តធម៌ មិនដែលបានសេចក្ដីសុខអំពីទីណាឡើយ ។ ដូច្នេះអ្នកល្អតែងស្រឡាញ់សេចក្ដីស្ងប់ទើបខំថែរក្សាតែសេចក្ដីស្ងប់រៀបរយ រក្សាតែសាមគ្គីធម៌ មិនបង្កឲ្យកើតការបាក់បែកគ្នាក្នុងរវាងបុគ្គល ឬគណៈ មិនសំដែងអាការរឹងរូស មុននឹងនិយាយតែងត្រិះរិះសិនទើបនិយាយ ហើយនិយាយទៅតាមតែរឿងដែលពិត ថែមទាំងធ្វើឲ្យពិតទៅតាមសំដីដែលនិយាយនោះទៀត មិនមែនជាមនុស្សបានតែមាត់ទេ ទាំងមិននិយាយឲ្យនរណាមួយបានទទួលទុក្ខលំបាក ឬ អៀនខ្មាសឡើយ ។

យើងនឹងទៅជាមនុស្សល្អ ដោយចូលចិត្តនឹងសេចក្ដីស្ងប់នោះ ត្រូវមានសតិសម្បជញ្ញៈគ្រប់ពេល កុំនិយាយទំលាក់ទោសលើអ្នកដទៃ ដើម្បី

ឲ្យខ្លួនរួចពីកំហុស  កុំធ្វើកុំនិយាយដោយអំណាច លោភ ក្រោធ វង្វេង ត្រូវមានចិត្តជាប្រក្រតីក្នុងពេលដែលជួបប្រទះនឹងលោកធម៌ទាំង ៨ ប្រការ បើធ្វើការណាមួយបានសម្រេច កុំរីករាយសប្បាយហួសហេតុ  កុំរួញរាចិត្តក្នុងពេលដែលធ្វើអ្វីមួយមិនសម្រេច ត្រូវអត់ធន់ចំពោះសេចក្តីឈឺចាប់នឹងពាក្យសំដីដែលគេពោលចាក់រុក  ត្រូវជួយខ្លួនឯង  កុំសូមឲ្យគេជួយ កុំខ្វល់ខ្វាយក្នុងការញុំាងអ្នកដទៃឲ្យសរសើរខ្លួន  តែកុំបួលចិត្តឲ្យអ្នកដទៃ ត្រូវគរហានិន្ទា  កុំត្រេកអរក្នុងលាភយសសម្បត្តិ  ដពបដល់ហួសហេតុ សូម្បីនឹងបានលាភយស  ក៏កុំក្អើតក្អើនពេក  ទោះបីថ្លស់យសស័ក្តិធ្លាក់ក្រដុនដាប  ក៏កុំទោមនស្សតូចចិត្តខូចចិត្តណាយៗដែរ ។

## ៣– អ្នកត្រូវតែងមានគោលមានទីតាំង –

គោលគឺគុណដែលទុកដូចជាសសរ ឬ ខ្លឹមដ៏រឹងប៉ឹង  សម្រាប់ទ្រទ្រង់ខ្លួនទុកឲ្យតាំងនៅបាន  បានដល់វិជ្ជាល្អដែលប្រៀបដូចពេជ្រនីលចិន្តាមណីដ៏មានដំឡៃ; ទីតាំងគឺគុណដែលទុកដូចជាកន្លែងទទួលរងដ៏មាំធំទូលាយ  សម្រាប់ទទួលទ្រទ្រង់ទុកបាន  បានដល់ចរិយាល្អដែលប្រៀបដូចសាច់មាសជាផ្ទាំងរងត្បូងពេជ្រ ។ អ្នកល្អរមែងដំកល់ខ្លួនឲ្យមានទឡាក់ឋាន ដោយការអប់រំគោលគឺគុណដែលជាសសរ ឬ ខ្លឹមដ៏រឹងប៉ឹងបានដល់វិជ្ជា  នឹងដោយការអប់រំទីតាំងគឺគុណដែលជាកន្លែងទទួលរងដ៏មាំបានដល់ចរិយាល្អ ។

## អ៊ីឡេណា - ស៊ិម្ប៉ាណា

### រឿងព្រេងប្រទេសរូម៉ានី

### លោក ផេង - ជឿវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

ក្នុងកាលដ៏កន្លងទៅហើយ មានព្រះចៅរាជាធិរាជមួយព្រះអង្គ ប្រកបដោយវិជ្ជានុភាពដ៏អស្ចារ្យ ព្រះអង្គបានបំបាក់បំបបស្តេចក្នុងជម្ពូទ្វីបទាំងមូលឲ្យលុះក្នុងអំណាចនៃព្រះអង្គ ហើយស្តេចចំណុះមួយៗ ត្រូវបញ្ជូនព្រះរាជបុត្រមួយអង្គៗ រៀងខ្លួន ឲ្យទៅនៅបំរើព្រះមហារាជអស់រាំងជប់ៗ ឆ្នាំគ្រប់ៗ គ្នា ។

ប៉ុន្តែក្នុងចំណោមស្តេចបរាជ័យទាំងប៉ុន្មាន មានព្រះរាជាមួយព្រះអង្គ តាំងពីនៅវ័យក្មេងមកទ្រង់មិនដែលបណ្តោយឲ្យព្រះចៅរាជាធិរាជវាយធ្វើបាបបានទេ ទ្រង់បេះប្រើកលល្បិចទាល់តែដែនរបស់ព្រះអង្គផុតស្រឡះពីសេចក្តីអន្តរាយ ៗ លុះដរាមកដល់ ទ្រង់គោងតែទទួលចំណុះព្រះចៅរាជាធិរាជវិញដដែល ៗ ប៉ុន្តែតើធ្វើដូចម្តេច ដើម្បីបញ្ជូនព្រះរាជបុត្រទៅ? បើទ្រង់មានតែរាជធីតាគ្មានព្រះរាជបុត្រសោះ ៗ ព្រះរាជាភ័យបារម្ភតប់ប្រមល់ក្នុងព្រះរាជហឫទ័យ ខ្លាចក្រែងព្រះចៅរាជាធិរាជនឹកស្មានថាព្រះអង្គជាស្តេចខ្មាំង ហើយមកវាយយកព្រះនគរ ធ្វើឲ្យព្រះអង្គព្រមទាំងរាជធីតាដល់នូវសេចក្តីទុក្ខវេទនានឹងអាប់កេរ្តិ៍ឈ្មោះ ។ –

ព្រះរាជធីតាទាំង ៣ អង្គ កាលបើឃើញព្រះបិតាទុក្ខព្រួយ ក៏យល់ហេតុមួយរំពេច ហើយនាំគ្នារកឧបាយផ្សេងៗ ដើម្បីកំចាត់សេចក្ដីព្រួយនោះចោលចេញ ប៉ុន្តែមធ្យោបាយទាំងប៉ុន្មានជាការឥតប្រយោជន៍ ។

មានមួយថ្ងៃ ពេលសោយក្រយាស្ងោយ ព្រះរាជធីតាច្បងលុតជង្គង់ ហើយក្រាបទូលសួរនូវហេតុ នៃសេចក្ដីទុក្ខរបស់ព្រះអង្គថា :

- បពិត្រព្រះបិតា? តើព្រះអង្គមិនសប្បាយព្រះហឫទ័យ មកពីអាការប្រព្រឹត្តនៃទូលព្រះបង្គំទាំងអស់គ្នាមិនសមរម្យឬដូចម្ដេច? ឬមួយអាណាប្រជារាស្ត្រចេះតែប្រឈ្លោះគ្នាពេក ធ្វើឲ្យព្រះអង្គព្រួយព្រះហឫទ័យ? បពិត្រព្រះបិតា! សូមព្រះអង្គមេត្តាប្រាប់យើងខ្ញុំឲ្យបានដឹងផងតើរឿងអ្វីបំពុលហឫទ័យរបស់ព្រះអង្គ? យើងរាល់រូបជាកូន សូមធានាអះអាងយកខ្លួនបូជាស្នងព្រះអង្គ ឲ្យតែព្រះអង្គបានធូរព្រះហឫទ័យ; បពិត្រព្រះបិតា! ព្រះអង្គគង់ជ្រាបច្បាស់ថា ទ្រង់ជាដួងជីវិតនៃទូលព្រះបង្គំគ្រប់គ្នា ហើយយើងខ្ញុំគោរពតែគោរពព្រះអង្គជាធម្មតា ឥតមានគិតមុខក្រោយឡើយ ។

- ការណ៍ហ្នឹងពិតមែនហើយ ប៉ុន្តែបិតាមិនមានតូចចិត្តអ្វីនឹងប្រជារាស្ត្រក៏ទេ, កូនស្រីទាំងអស់គ្នា ក៏មិនបានប្រព្រឹត្តអ្វីឲ្យជាធំទាស់ដល់មតិនៃបិតាក៏ទេដែរ ។ ម្នាលកូនសម្លាញ់! តាមបិតាគិតទៅឃើញថា នាងទាំងអស់គ្នាមិនអាចនឹងកំចាត់បង់នូវសេចក្ដីទុក្ខព្រួយ ដែលមាននៅ

កូនដូនព្រះហឫទ័យនៃបិតាឡើយ ។ កូនកល់គ្នាសុទ្ធតែស្រីៗ ហើយមានតែកូនប្រុសទេ ដែលអាចដកសេចក្ដីទុក្ខចេញពីខ្លួនបិតាបាន ។

កូនស្រីច្បងក្រាបទូលសួនឡើងថា: បពិត្រព្រះបិតា! តើហេតុដូចម្ដេចក៏ព្រះអង្គលាក់សេចក្ដីទុក្ខព្រួយនឹងទូលព្រះបង្គំ? សូមទ្រង់មានព្រះឧត្ដារមកចុះ ចំណែករូបខ្ញុំម្ចាស់មួយគឺប្រុងតែនឹងយកជីវិតទៅបូជាថ្វាយជំនួសព្រះអង្គ ។

ព្រះរាជាមានព្រះបន្ទូលឆ្លើយថា: ម្នាលកូនស្រីសំឡាញ់បិតា! តើកូនឯងនឹងធ្វើដូចម្ដេចកើត? តាំងពីកូនប្រសូតចាកឧទរព្រះមាតាមកកូនឯងមានតែខ្មារ, មានតែម្ហូល, មានតែកីជាគ្នា កូនឯងចេះតែការអម្បោះ ដេរហើយនឹងត្បាញ ។ ដើម្បីដោះទុក្ខបិតាគឺត្រូវជាអ្នកខ្លាំងពូកែចេះកាន់គ្រឿងអាវុធ ចេះកាន់ព្រះខ័នដោយត្រឹមត្រូវ ហើយឲ្យចេះជិះសេះយ៉ាងស្ទាត់ជំនាញ យ៉ាងលឿនដូចជាយក្ស ។

- បពិត្រព្រះបិតា! ទោះបីយ៉ាងដូចម្ដេចក៏ដោយ សូមព្រះអង្គមានព្រះបន្ទូលមកចុះ តើហេតុនៃសេចក្ដីព្រួយរបស់ទ្រង់នោះដូចម្ដេច? ។

- ម្នាលកូនស្រី! ហេតុនៃសេចក្ដីទុក្ខបិតានោះដូច្នេះ កាលបិតានៅក្មេង, កូនស្រីគង់មិនលែងដឹងខ្លះ គ្មាននរណាហ៊ានមកប្រមាថមើលងាយដល់ព្រះនគរបិតាទេ គ្មាននរណាធ្វើឲ្យបិតាអាប់កេរ្តិ៍ឈ្មោះឡើយ ។ ឥឡូវពេលជរាមកបៀតបៀនធ្វើឲ្យបិតារកកម្លាំងនឹងលើកអាវុធ

ដើម្បីកំឡាសត្រូវមិនបាន ។ រាជអស្សពាហន៍ដែលជាព្រះរាជទីនាំងក្នុងបម្រាំងក៏ចាស់ៗអស់ ឃើញមាននៅសល់តែសេះកញ្ចាស់មួយដែលសព្វថ្ងៃរស់នៅទាំងត្រដរ ខ្លួនអង្គែស៊ីអស់ ។ កាលពីដើម បើបិតាចេញទៅកន្លែងណា សត្រូវរត់ខ្ចាត់ខ្ចាយអស់ ចុះឥឡូវ ... ។ ណ្ហើយកុំនិយាយច្រើន! កូនស្រីដឹងឬទេ? បិតាត្រូវបំណុះព្រះចៅរាជាធិរាជដែលមានបុណ្ណានុភាពលើផែនដីទៅហើយ ។ តាមទំលាប់ព្រះចៅអង្គនោះគឺត្រូវស្តេចចំណុះបញ្ជូនកូនប្រុសម្នាក់ឲ្យទៅនៅបំរើព្រះអង្គអស់រយៈវេលា ១០ ឆ្នាំ ហើយបិតាមានតែនាងពលគ្នា តើធ្វើដូចម្តេច? ។

កូនស្រីច្បងឆ្លើយថា: បពិត្រព្រះបិតា! ទូលព្រះបង្គំសូមយកខ្លួនទៅបំរើជំនួស ដើម្បីឲ្យព្រះបិតាសប្បាយព្រះហឫទ័យ ។

— ម្នាលកូនស្រីបិតា! ក្រែងកូនឯងត្រឡប់មកវិញឥតកើតការ ហើយរឹតតែធ្វើការនេះឲ្យកាន់តែមានឧបសគ្គខ្លាំងឡើងទេដឹង! ។

— បពិត្របិតា! របស់ដែលទូលព្រះបង្គំបេះ គឺព្រះអង្គនឹងមិនត្រូវមានសេចក្តីអៀនខ្មាស ពីព្រោះតែទូលព្រះបង្គំទេ ។ សំដីនេះគឺជាសំដីពិត ទូលព្រះបង្គំសូមសន្យាទុកជាមុន ។

— បើដូច្នោះ, ចូរកូនប្រុងប្រៀបរៀបចំអាត្មានឹងចេញទៅចុះ ។

លុះបានឮសំដីដូច្នោះ, នារីមានសេចក្តីសប្បាយចិត្តរកអ្វីប្រៀបគ្មាន ។ នាងចាប់រៀបចំប្រដាប់ប្រដាយ៉ាងរហ័សរួសរាន់នឹងធ្វើដំណើរ រួចនាង

ទៅរើសយកសេះដែលល្អឆើតជាប់គេនៅក្នុងព្រះរាជក្រោល ហើយយកគ្រឿងសម្លៀកបំពាក់សុទ្ធតែមានដំឡៃ ព្រមទាំងផ្ទុកស្បៀងសម្រាប់បរិភោគអស់រយៈពេលមួយឆ្នាំ ។

កាលណាព្រះរាជាទ្រង់ទតឃើញកូនស្រីរៀបចំស្រេចហើយ ព្រះអង្គទ្រង់ប្រទានដំបូន្មានថា ត្រូវប្រយ័ត្នកុំឲ្យគេដឹងភេទរបស់អាត្មា តើអ្នកខ្លាំងមានរិទ្ធិត្រូវទៅបំរើស្តេចជាចៅហ្វាយនាយបែបដូចម្តេច ប្រាប់ឲ្យប្រុងខ្លួនអំពីការនិយាយដើមអ្នកដទៃ អំពីការនិយាយបង្កាច់ បើយើងចង់កុំឲ្យមានសេចក្តីគំនុំគុំគួន និងការមើលងាយអំពីសំណាក់នៃកូនស្តេចប្រទេសរាជដទៃ ។ ព្រះរាជាមានព្រះបន្ទូលខាងចុងបំផុតថាៈ សូមឲ្យព្រះជាម្ចាស់តាមរក្សាកូនស្រីជានិច្ច ហើយចូរកូនកុំភ្លេចពាក្យដំបូន្មានបិតា ។

ឯនាងមាណវិកជធីតា ធ្វើដំណើរចេញទៅលឿនដូចព្រួញ ព្រោះព្រះនាងមានសេចក្តីសប្បាយពេក មិនយូរប៉ុន្មានក៏បានទៅដល់ទីក្រៅក្រុង ។ ពួកអ្នកតាមបំរើនិងរទេះផ្ទុកស្បៀង កុំតែព្រះនាងនៅរង់ចាំ មុខជារង្វើងផ្លូវ ព្រោះតាមនាងពុំទាន់ ។ ប៉ុន្តែព្រះរាជាជាបិតា លួចទៅចាំស្កាត់យ៉ាងឆ្ងាយពីខាងមុខនាងដោយផ្លូវម្ខាងមិនឲ្យនាងដឹង ។ ព្រះអង្គនិម្មិតជាស្ពានដែក រួចដំណែងខ្លួនជាចចកទៅពួនចាំក្រោមស្ពាននោះ ។ លុះព្រះរាជធីតាទៅដល់ស្ពានបំរុងនឹងឆ្លង ព្រះរាជាស្ទុះឡើងបញ្ចេញចង្កូម

សស្វាច ក្អែកសំឡក់ទៅរកក្ដីចាំងដូចចង្កុះមួយគូ រួចស្ទុះសំដៅទៅរកនាង ដើម្បីនឹងចាំត្របាក់ស៊ី ។ នាងស្រីគ្រមុំភ័យតក់ស្លុតស្ទើរបាត់ស្មារតី ហើយប្រសិនបើសេះកុំហក់លោតស្ទុះទៅគៀនម្ខាង ប្រហែលនាងនឹងត្រូវដោយចង្កូមចចកជាមិនខាន ។ ភ័យពេក ធីតាទាញបង្ហៀរសេះបរបំផាយវិលត្រឡប់ចូលព្រះនគរវិញ ។ ប៉ុន្តែព្រះរាជាជាបិតាវិលត្រឡប់តាមផ្លូវកាត់មកដល់មុននាង ហើយចូលមករកនាងនិយាយថា ៖ ម្នាលកូនស្រីព្រះបិតា ម៉េចហ្ន៎ ! បិតាបាននិយាយប្រាប់នាងមែនឬទេ ថាសត្វរុយមិនដែលធ្វើទឹកឃ្មុំកើតទេ? ។

– បពិត្រព្រះបិតា ! ករណីហ្នឹងពិតដូច្នោះមែនហើយ ប៉ុន្តែទូលព្រះបង្គំមិននឹកស្មានថាការដែលទៅបំរើព្រះចៅរាជាធិរាជនោះ ត្រូវតែច្បាំងជាមួយនឹងសត្វតិរច្ឆានព្រៃសាហាវយង់ឃ្នងផងឡើយ ។

ព្រះរាជាមានព្រះរាជឱង្ការថា ៖ ឥឡូវបើដូច្នោះហើយ ចូរកូននៅនឹងប្រាសាទចំដេរប៉ាក់ត្បាញ រវៃទៅចុះល្អជាជាង ។ ព្រះជាម្ចាស់ប្រហែលជាអាណិតបិតាធ្វើមិនឲ្យបិតាមរណកាលទៅទាំងអាប់កេរ្តិ៍ឈ្មោះទេ ។

លុះកាលកន្លងទៅមិនយូរប៉ុន្មាន កូនស្រីបន្ទាប់ក៏សុំខ្លួនទៅម្ដង ហើយតាំងសន្យាថា ៖ នឹងខំប្រឹងធ្វើដូចម្ដេចឲ្យបានកិច្ចនុះសម្រេចដល់ទីបំផុត ។ ខាងក្រោយការខំទទូចសុំ នឹងការសន្យាជាច្រើនបែប ច្រើនស្ពាន ព្រះរាជាក៏ទ្រង់យល់ព្រមបើកឲ្យទៅ ។ ប៉ុន្តែនាងគ្រមុំនេះក៏ត្រូវ

ទទួលគ្រោះថ្នាក់ ហើយត្រូវវិលមកព្រះនគរវិញដូចជាព្រះរាជធីតាច្បងដែរ ហើយព្រះរាជាទ្រង់បន្ទោសថា: ម្នាលកូនស្រី ម៉េចហ្ន៎! បិតាមិនបាននិយាយប្រាប់កូនស្រីឬទេ ថាវត្ថុដែលភ្លឺចាំងមិនមែនមាសទេ? ។

– បពិត្រព្រះបិតា! ករណីហ្នឹងប្រាកដមែនហើយ បិតានិយាយត្រូវមែន ប៉ុន្តែទាស់ចបកនោះសម្បើមពេក, វាហាមាត់បែបជាចង់ត្របាក់លេបទូលព្រះបង្គំទាំងមូលតែម្តង ហើយពន្លឺភ្នែកវាស្រួចដូចព្រួញដែលបំរុងនឹងចាក់ដើមទ្រូងទូលព្រះបង្គំជាខ្ញុំ ។

ព្រះរាជាមានព្រះរាជឱង្ការទៀតថា: បើដូច្នោះ ចូរកូនអាស្រ័យនៅនឹងវាំងហើយ គិតតែពីដេរប៉ាក់ ស្ងួនណ្ដាំទៅល្អជាជាង ។

បីបួនថ្ងៃក្រោយមកទៀត វេលាកំពុងសោយព្រះស្ងោយ រាជធីតាពៅទៅក្រាបបង្គំទូលឡើងថា: បពិត្រព្រះវររាជបិតា! សូមព្រះរាជាមេត្តាបើកឲ្យទូលព្រះបង្គំជាខ្ញុំចេញទៅល្បងមើលម្តងផង ទូលព្រះបង្គំចង់ផ្សងវាសនាម្តងដែរ ក្រែងបុណ្យកូនមាន ។

– ឱព្រះជាម្ចាស់បិតាអើយ! បងស្រីទាំងមួយទាំងពីរបានធ្វើឲ្យបិតាពិបាកចិត្តឥតគណនាទៅហើយ, ចុះកូនឯងមករកអ៊ីនឹងគេដែរ បើស៊ីតែបាយសឹងមិនទាន់ត្រង់មាត់ផង ។ ព្រះរាជាខំប្រឹងប្រើវិធានការដើម្បីបង្វែរបំណងនុះចេញ ប៉ុន្តែឥតអំពើ ។

ព្រះរាជធីតាអង្វរទៀតថា: ទូលព្រះបង្គំខំប្រឹងលុះត្រាតែកិច្ចនោះសម្រេច ហើយប្រសិនបើព្រះជាម្ចាស់លោកមកជំទាស់ធ្វើឲ្យទូលព្រះបង្គំវិលត្រឡប់មកព្រះនគរវិញ នោះទូលព្រះបង្គំក៏មិនមានសេចក្ដីអៀនខ្មាសឡើយ ។

ព្រះរាជានៅតែមិនយល់ព្រម ហើយប្រើកលដើម្បីបន្ទាបនាង ប៉ុន្តែធីតានៅតែទទូចសុំ លុះទីបំផុតព្រះរាជាត្រូវតែយល់ព្រមតាមសេចក្ដីសុំ ។

ព្រះរាជាមានព្រះរាជឱង្ការថា: ចូរកូនល្បងរកសនាមើលចុះ បិតាចាំមើល តើកូនឯងធ្វើដូចម្ដេចនឹងអាចបានទៅរួច បិតាមុខជាបានសើចទៀត ដោយកូនឯងត្រឡប់មកវិញជាក់មុខជប់ជាមិនខាន ។

— បពិត្រព្រះបិតា ! ព្រះអង្គទៀងតែនឹងបានទ្រង់ព្រះសំណើចនឹងទូលព្រះបង្គំ ដូចជាព្រះជេដ្ឋធីតាមុនៗជាប្រាកដ ប៉ុន្តែសូមព្រះអង្គទ្រង់ព្រះសំណើចចុះ កុំឲ្យតែខ្ញុំម្ចាស់ប្រកបដោយកេរ្តិ៍ឈ្មោះអាក្រក់ពីព្រោះរឿងនេះ ។

ពេញព្រះហឫទ័យនឹងការយល់ព្រមរបស់ព្រះរាជបិតា ព្រះរាជធីតាពៅ មុនដំបូងគិតរកទីប្រឹក្សានូវបណ្ដាពួកនាម៉ឺនចាស់ៗ រួចនាងនឹកឃើញភ្លាម នូវរឿងចម្បាំងនៃបិតាកាលដែលទ្រង់នៅពីក្មេង នូវសេះតាំងឡាយយ៉ាងជំនាញៗរបស់ទ្រង់ ។ ព្រះនាងទៅឯទីព្រះរាជក្រោល

ដើម្បីរកជ្រើសរើសនូវព្រះរាជពាជី ៗ ព្រះនាងទ្រង់ទតព្រះនេត្រចំពោះអាជានេយ្យទាំងឡាយទាំងអស់ ទោះជាមានរូបរាងឆើតឆើយល្អយ៉ាងណា ក៏គ្មានសេះណាមួយត្រូវចំណុចព្រះហឫទ័យនៃព្រះនាងឡើយ ៗ លុះទីបំផុត ព្រះនាងបានប្រទះសេះកញ្ចាស់មួយដេកនៅគៀនក្រោលចាស់ជរា ខ្លួនមិនជាប៉េប៉ឺ សុទ្ធតែអង្គែ សុទ្ធតែរមាស់ គឺជាព្រះរាជ-អស្សពាហន៍ចាស់នៃព្រះវរបិតា, លុះឃើញអាការៈវិកលវិការដូច្នោះ ព្រះនាងមានព្រះហឫទ័យករុណាមិនអាចដើរចេញទៅឆ្ងាយពីសេះទុះបានុ ៗ

ខណៈនោះសេះមានវាចាទៅកាន់ព្រះរាជធីតាថា: ប្រាកដមែនហើយម្ចាស់ ! ទ្រង់ទតមើលទូលព្រះបង្គំប្រកបដោយសេចក្ដីមេត្រីដូច្នេះ ព្រោះទ្រង់មានចិត្តស្នេហាចំពោះព្រះមហាក្សត្រិយ៍ ៗ កាលនៅពីកំឡោះព្រះបរមក្សត្រិយ៍មានសេចក្ដីក្លាហានខ្លាំងណាស់ មិនដឹងជាប៉ុន្មានលើកប៉ុន្មានគ្រា ព្រះអង្គមានជ័យជំនះជាមួយនឹងទូលព្រះបង្គំ ៗ ប៉ុន្តែតាំងពីព្រះរាជាដល់នូវសេចក្ដីជរាកាលណា គ្មាននរណាជិះលើទូលព្រះបង្គំសោះ ទាំងគ្មាននរណាបេះថែទាំទូលព្រះបង្គំឡើយ បានជាទ្រង់ឃើញទូលព្រះបង្គំប្រោបពេមអស់រលីងដូច្នោះ ៗ សព្វថ្ងៃនេះក៏ដោយ បើគេផុសលាងទូលព្រះបង្គំតែ ១០ ថ្ងៃ, សេះទាំង ១០ នេះមិនស្មើទូលព្រះបង្គំតែមួយឡើយ ៗ

(មានត)

## សព្ទបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

# លោកម៉ុញ - ត៉ាគ្រី អតីតតំណាងរាស្ត្រ រួបរួម

(តមក)

---

Couleur bleu marine = ពណ៌ជ្រះ

Pharmacien = ឱសថការី (ស. ឱសថការិនី)

Proviseur = នាយកវិទ្យាល័យ

Censeur de Lycée = សិក្សាធិការ វិទ្យាល័យ

Sous la juridiction = ក្នុងកំឡុងច្បាប់

Sous l'autorité = ក្រោមអំណាច

Ophtalmologie = ចក្ខុរោគសាស្ត្រ

Institut ophtalmologique = វិជ្ជាស្ថានចក្ខុរោគ

(១៤-១២-៥០)

Spéléologie = គុហាសាស្ត្រ

Tunnel = ឧមង្គ (អុម-ម៉ង)

Epreuves écrites = វិញ្ញាសាសរសេរ

Epreuves orales = វិញ្ញាសាសួរ

Epreuves pratiques = វិញ្ញាសាប្រតិបត្តិ

Concierge = គេហបាល

Portier = ទ្វារបាល

Valet de pied = អ្នកបំរើក្រៅ

Valet de chambre = អ្នកបំរើក្នុង

Saint-Siège = សន្តនិកេតន៍

(១៩-១២-៥០)

Garniture = អលង្ការណ៍ (គ្រឿងសម)

Broc = តយទឹក

Chauffe-eau = ប្រដាប់កំដៅទឹក

Piano = ព្យាណូ

Canapé = កៅអីវែង

Fauteuil = កៅអីក្អាក់ដៃ

Réfrigérateur = ទូទឹកកក

Console = តុរបនា

Secrétaire (Mobilier) = តុសរសេរ

Commode = មញ្ជូសា (ទូតូចមានថត)

Armoire = ទូ

(២២-១២-៥០)

Joyau = រតនរត្ន

Cristaux = គ្រឿងចរណៃ

Verrerie = គ្រឿងកែវ

Faïence = ហ្វេយ៉ង់

Porcelaine = ពារ្សឺឡែន

Poterie = កុម្ភការភណ្ឌ

Pinge d'office = សំពត់ជូត

Billard = ប៊ីយ៉ារដ៍

Picup = ពីគឹប

Equipage = យានិក, បរិជន

Passager = យានបរ

(២៦-១២-៥០)

Corps diplomatique = អគ្គទូត

Corps consulaire = អគ្គកុងស៊ុល

Ambassadeur itinérant = អគ្គរាជទូតគោចរ

Chargé extraordinaire = ធារីវិសាម័ញ្ញ

Conseiller d'Ambassade = ទីប្រឹក្សាស្ថានឯកអគ្គរាជទូត

Conseiller de Légation = ស្ថានអគ្គរាជទូត

1er Secrétaire d'Ambassade = លេខាធិការទី ១ នៃស្ថានឯកអគ្គរាជទូត

2e Secrétaire d'Ambassade = លេខាធិការទី ២ នៃស្ថានឯកអគ្គរាជទូត

Attaché d'Ambassade = អនុព័ន្ធស្ថានឯកអគ្គរាជទូត

Attaché commercial = អនុព័ន្ធស្ថានឯកអគ្គពាណិជ

Attaché culturel = អនុព័ន្ធវប្បធម៌

Attaché militaire = សេនានុព័ន្ធ

(២៩-១២-៥០)

Centre Régional = មជ្ឈមណ្ឌលភូមិភាគ

Centre de Recherches Scientifiques et Techniques = មជ្ឈមណ្ឌលនៃការស្វែងរកខាងវិទ្យាសាស្ត្រនឹងតិកនិក

Centre Mondial = មជ្ឈមណ្ឌលពិភពលោក

Recommandation អនុសាសន៍

Recommandé = អនុសិដ្ឋ

Adresse = អាសយដ្ឋាន

Stimuler = បណ្ដុះបណ្ដាល

Institution = ស្ថាប័ន

(៥-៤-៥១)

Membre ex-officio = សន្និសមាជិក

Voix prépondérante = សំឡេងមានប្រៀប, សំឡេងកាត់សាញ

Contribution = ភាគទាន

(៨-១-៥១)

chèque = ឆែក, មូលប្បទានប័ត្រ

Don = ទាន

Donateur = ទាយក

Donation = អំណោយ

Donatrice = ទាយិកា

Dotation = ទាយជ្ជទាន

Concession = សម្បទាន

(១២-១-៥១)

Revue «La Pensée Bouddhique» = ទស្សនាវដ្ដី "ពុទ្ធចិន្ដា"

Un forestier = ត្រពាំង

Chapitre . កថាភាគ

Paragraphe = កថាខណ្ឌ

Alinéa = វាក្យខណ្ឌ, វគ្គ

(១៦-១-៥១)

(មានត)

# រឿងសាមកុក

ភាគទី ៩

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកភាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯប៊ូឆូឃើញតូកៀមលើកទាហានចេញមក ក៏ឡើងសេះជិះតម្រង់ទៅមុខទាហាន ឲ្យទាហានទាំងអស់ពាយគ្នាជាបែកឆ្វេងស្តាំ ។ តូកៀមក៏ឡើងសេះជិះតម្រង់ទៅ បញ្ចេញខ្លួនទទួលគំនាប់ប៊ូឆូហើយនិយាយថា ពីដើមខ្ញុំប្រុងខ្លួននឹងចូលទៅធ្វើរាជការជាមួយនឹងលោកជាប្រាកដ លុះឃើញបិតាលោកលើកគ្រប់គ្រមកដល់ខែត្រខ្ញុំ ក៏បានគួរសមទទួលនាំទៅឈប់ស្នាក់លើទីគ្រឹហស្ថាន បានទាំងរៀបភោជនាហារដ៏ប្រសើរឲ្យពីសាជាទីពប់អាន ហើយខ្ញុំបានចាត់ប្រើតៀវឃើឲ្យនាំទាហានជូនដំណើរបិតាលោកទៅទៀតប្រាថ្នានឹងជួយការពារអន្តរាយ ហើយប្រាថ្នា

ទឹងឲ្យបានសេចក្តីគាប់ប្រសើរពីលោកផង តែថាគៀវឃើញមនុស្សទុច្ចរិតប្រែចិត្តចេញពីខ្ញុំនាំបិតាលោកទឹងបក្សពួកទៅសម្លាប់យកទ្រព្យ ខ្ញុំទឹងបានបង្គាប់ឲ្យធ្វើដូច្នោះក៏ទេ ដែលលោកមកខឹងនឹងខ្ញុំជាគំនុំគុំគួនខ្លាំង ហើយលើកទាហានមកច្បាំងសម្លាប់អ្នកស្រុក ដែលមិនមានទោសខុសផងនោះខ្ញុំឃើញថាមិនគួរណាស់ សូមលោកគិតមើលដោយគួរសិនចុះ ។ ចូចុក្តដូច្នោះខឹងប្រឡាតដេរប្រមាថតូកៀមជាពាក្យអាស្រូវកាសផ្សេងៗ ហើយស្រែកថា "អាឯងប្រើឧបាយកលពន្យល់ឲ្យទាហានសម្លាប់បិតាអញនឹងបក្សពួកអស់ជាប្រុកដ ហើយមកបើកមាត់និយាយកែខ្លួន សុទ្ធតែពាក្យសំនួនគួរសមល្អណាស់" ហើយស្រែកប្រកាសថា នរណាទឹងទទួលយកអាសាទៅចាប់ខ្លួនតូកៀមឲ្យយើងបាន ។ វែហាហ្មូនឆ្លើយទទួលយកអាសាឡើងជិះសេះចេញទៅទឹងចាប់តូកៀម ចូប៉ាឃើញហើយបរសេះចេញមកតយុទ្ធគ្នាទឹងវែហាហ្មូនបាន ៩ ភ្លែង ទទួលកើតខ្យល់ព្យុះធ្លាក់ភ្លៀងរំលាជាខ្លាំង ពួកពលដែលកំពុងច្បាំងក៏ថយទៅឈប់តែសព្វខ្លួន ។ ឯតូកៀមកាលត្រឡប់ចូលទៅក្នុងស្រុកហើយ ក៏ប្រឹក្សាទឹងសេនាទាហានទាំងពួងថា ទាហានរបស់យើងទឹងតស៊ូទ័ពចូចុមិនបានទេ បើប្រឹងច្បាំងទៅកាលណា បណ្តាទាហានទឹងអាណាប្រជានុរាស្ត្រក្នុងស្រុកទឹងស្លាប់អស់ហើយ បើដូច្នេះគួរតែអ្នកពល់គ្នានាំយកខ្លួនយើងទៅចងចំណងឲ្យជាប់ ហើយនាំទៅឲ្យចូចុតែម្តងចុះ ទើបបានរួចរស់ជីវិតទាំងអស់គ្នា ។

ក្នុងពេលនោះ មានឈ្មោះបិតុកពួកអ្នកស្រុកគងហៃ កាលពីដើម ធ្វើជំនួញលក់ដូរមានទ្រព្យសម្បត្តិច្រើន គាត់នាំគ្នាទៅលក់ឯស្រុកឡុកអៀងនោះ លុះលក់អស់ហើយក៏បររទេះត្រឡប់មកវិញ ៗ មានស្រីម្នាក់រូបល្អស្រស់ប្រហែលអាយុ ១៦ ឆ្នាំ សុំដោយសាររទេះបិតុកមកស្រុកគងហៃផង ៗ បិតុកៈ យាគយល់អាណិតដ្បិតជាស្រី ក៏ប្រណីឲ្យឡើងជិះរទេះ ឯខ្លួនឯងក៏ចុះដើរទៅ ស្រីនោះនិយាយថា ខ្លួនខ្ញុំជាអ្នកដោយសារទើងអង្គុយលើរទេះឲ្យម្ចាស់ចុះដើរមិនគួរសោះ បើដូច្នេះអ្នកឡើងមកជិះវិញចុះ ៗ បិតុកក៏ឡើងបរអង្គុយពីមុខ ស្រីនោះអង្គុយពីក្រោយ ខ្លួនបិតុកនឹងបានក្រឡេកមើលឲ្យស្គាល់ស្រីនោះជាយ៉ាងម្តេចក៏ទេសោះ ៗ លុះបរទៅដល់ស្រុកគងហៃ ស្រីនោះនិយាយថា "ខ្លួនយើងមិនមែនជាមនុស្សទេ គឺជាស្រីទេពអប្សរ ទេវតាជាធំប្រើឲ្យយើងយកភ្លើងមកដុតផ្ទះអ្នកឯង ទើបយើងក្លែងសុំជិះរទេះដោយលចិត្តមើលឃើញថាអ្នកឯងមិនធ្វើអន្តរាយដល់ខ្លួនយើងនោះ គឺចិត្តអ្នកសុចរិតត្រង់ល្អមែន ប្រសិនជាយើងនឹងមិនយកភ្លើងទៅដុតផ្ទះអ្នក ក៏ឃើញថាខុសនឹងបង្គាប់ទេវតាជាធំ បើដូច្នេះអ្នកប្រជញ្ជូនទ្រព្យរបស់ពីក្នុងផ្ទះអ្នកចេញឲ្យអស់ក្នុងវេលាយប់នេះ យើងនឹងយកភ្លើងដុតផ្ទះចេញតាមពាក្យទេវតា" លុះនិយាយប្រាប់ដូច្នេះហើយ ស្រីនោះក៏អន្តរធានបាត់ទៅ ៗ បិតុកបានឃើញដូច្នេះ ក៏មានសេចក្តីអស្ចារ្យក្នុងចិត្តណាស់ ទើបរៀសរៀវទៅដល់ផ្ទះហើយ ចាត់ឲ្យ

ដញ្ជូនរើយកទ្រព្យរបស់អស់ពីក្នុងផ្ទះ ៗ ដល់ពេលអធ្រាត្រស្ងាត់ ស្រាប់តែបណ្ដាលភ្លើងឆេះផ្ទះបិតុកអស់រលីង  ឯទ្រព្យរបស់ដែលដញ្ជូនចេញទៅនោះ  បិតុកលើកឲ្យទៅជាទានសព្វយាចកអស់គ្មានសល់  កិត្តិសព្ទនោះក៏ឮខ្ចរខ្ចាយទៅដល់តួកៀម ៗ ចាត់ឲ្យមនុស្សទៅយកខ្លួនបិតុកមកទុកជាទីប្រឹក្សា  ៗ

កាលបិតុកបានឮតួកៀមព្រមឲ្យគេចាប់ខ្លួនទៅជូនចូចូដូច្នោះ  បិតុកក៏ឆ្លើយទាស់ថា លោកជាទីចៅហ្វាយស្រុកឈីជីវ  សន្ដានចិត្តរបស់លោកប្រកបដោយសុចរិតពិតត្រង់  ទាំងមានមេត្តាករុណាដល់ប្រជានុរាស្ត្រជាជ្រៅទូលាយណាស់,  ដែលលោកនឹងឲ្យចងខ្លួនលោកទៅឲ្យចូចូនោះមិនសមគួរទេ  បណ្ដារាស្ត្រទាំងពួងនឹងអស់ទីពឹងពុំនាក់សោះ  លោកត្រូវតែគិតកេណ្ឌកងសេនាទាហានឲ្យបានគ្រប់គ្រាន់ ហើយឲ្យឡើងរក្សាសែនបន្ទាយឲ្យមាំមួនចុះ  បើធ្វើដូច្នោះឃើញថា  ចូចូនឹងពុះពារទំលាយដោយងាយមិនបាន  មួយទៀតសុំឲ្យលោកធ្វើសំបុត្រឲ្យខ្ញុំកាន់ទៅសុំកងទ័ពខុងយ៉ុងចៅហ្វាយស្រុកប៉ាក់ហៃ  យកមកជួយតតាំងច្បាំងនឹងចូចូ ១ ច្បាប់,  មួយច្បាប់ទៀត  ឲ្យចាត់ប្រើទាហានកាន់សំបុត្រទៅសុំកងទ័ពតេងកៃចៅហ្វាយស្រុកឈៀងជីវមកជួយផង  ទុកជាកងទ័ពសន្ធប់ខ្ទប់វាយទ័ពចូចូក៏គង់តែនឹងបែកមិនខាន ៗ តួកៀមបានស្ដាប់ហើយយល់ឃើញត្រូវ ទើបសួរទៅបិតុកថា នរណានឹងទទួលយកអាសាកាន់សំបុត្រទៅឲ្យ

តេងកែ ៗ គាត់តែងឆ្លើយថា ខ្ញុំបានសូមទទួលអាសា ៗ តួកៀមក៏ឲ្យធ្វើសំបុត្រប៉ោះត្រាប្រគល់ឲ្យបិតុកនឹងគាត់តែងកាន់យកទៅខណៈនោះ ៗ

ឯខុងយ៉ុងចៅហ្វាយស្រុកប៉ាក់ហៃ ជាមនុស្សមានចិត្តធូរទូលាយស្រឡាយគប់ប្រសព្វពួកម៉ាកជាច្រើនណាស់ បណ្ដាក្រុងស្រុកមានសេចក្ដីមេត្រីរាប់អាន ៗ ខុងយ៉ុងនោះមានទាហានមកទទួលទានអាហារលើផ្ទះ លុះឃើញបិតុកយកសំបុត្រទៅដល់ ក៏មើលដឹងសេចក្ដីហើយថា តួកៀមនឹងយើងជាមនុស្សស្រឡាញ់រាប់អានគ្នាមកយូរ ខាងបូព្វមិនដែលមានរឿងអ្វីនឹងយើងដូចគ្នា បើយើងនឹងធ្វើសំបុត្រទៅហាមឃាត់ បូព្វក៏ប្រហែលនឹងស្ដាប់ពុំខាន បើត្រឡប់ជាមិនស្ដាប់យើងវិញ សុំយើងលើកទ័ពទៅជួយតួកៀមជាក្រោយ ៗ បិតុកតបថា បូព្វនោះខឹងគុំគួននឹងតួកៀមជាប្រើកលឧបាយសម្លាប់បុក្កូជាបិតា បើលោកនឹងឲ្យសំបុត្រទៅឃាត់វេលាណាខ្ញុំឃើញថា បូព្វគង់មិនស្ដាប់ ខាងនេះបង់ប្រញាប់ក៏នឹងនាំឲ្យយូរការ ៗ ខុងយ៉ុងឆ្លើយថា អ្នកនិយាយដូច្នេះត្រូវណាស់ យើងនឹងប្រើបំរើយ៉ាងរហ័សឲ្យកាន់សំបុត្រទៅ ឯទាហានខាងនេះក៏យើងត្រូវកេណ្ឌបញ្ជូនឲ្យចេញទៅព្រមជាមួយគ្នាតែម្ដង ៗ

កាលកំពុងនិយាយគ្នានោះ មានបំរើសេះមកជំរាបខុងយ៉ុងថា កួនហៃយុំនាំពួកចោរជួតក្បាលលឿងប្រហែល ៤-៥ ម៉ឺន លើកចូលមកជិតដល់ស្រុកយើងហើយ ៗ ខុងយ៉ុងព្រួយប្រាស់ក៏មានសេចក្ដីភ័យណាស់រលះ

រលាំងតាំងតែឲ្យកេណ្ឌទាហានលើកទៅតទល់នឹងពួកចោរ ។ ក្ដួនហៃឡើងជិះសេះបរចេញមកមុខទាហានហើយស្រែកហៅខុងយ៉ុងថា ដែលយើងលើកទ័ពមកនេះប្រាថ្នានឹងរកស្បៀងអាហារ បើអ្នកព្រមឲ្យស្បៀងយើងមួយម៉ឺនថាំង យើងនឹងលើកត្រឡប់កងទ័ពទៅវិញ បើអ្នកមិនព្រមឲ្យយើងទេ យើងនឹងលើកកងទ័ពខ្ទប់វាយយកស្រុកនេះឲ្យបាន ហើយឲ្យសម្លាប់កិរិយាបុត្រនឹងញាតិសន្ដានមិនឲ្យមានសល់ ។

ខុងយ៉ុងស្រែកតបថា ខ្លួនយើងជាមន្ត្រីមានបណ្ដាសក្ដិរក្សាខបខ័ណ្ឌសីមារបស់ព្រះមហាក្សត្រ ខ្លួនឯងជាចោរកំណាចទុច្ចរិត, ដែលឯងមកគិតកំហែងឲ្យយើងជូនស្បៀងទៅឲ្យនោះ យើងមិនត្រូវការឲ្យទេ, បើឯងខ្លាំងពូកែនឹងចង់វាយទំលាយយកស្រុកយើងក៏តាមចិត្តឯងចុះ យើងមិនខ្លាចទេ ។

ក្ដួនហៃខឹងណាស់ ជិះសេះកាន់ដាវចូលប្រយុទ្ធនឹងខុងយ៉ុង ចុងប៉ោទាហានខុងយ៉ុងក៏ឡើងសេះចេញទៅតទល់នឹងក្ដួនហៃបាន ៥ ស្ទើត, ក្ដួនហៃយកដាវកាប់ចុងប៉ោធ្លាក់ពីលើសេះស្លាប់, ខុងយ៉ុងឃើញថានឹងទប់ទល់ពុំឈ្នះក៏ត្រូវរះថយទាហានចូលទៅក្នុងស្រុកវិញ ។ ក្ដួនហៃលើកពលទាហានចោរឡោមព័ទ្ធជុំវិញស្រុកនោះច្រើនថ្ងៃ ឯបិតុកដែលត្រូវកៀមឲ្យនាំសំបុត្រមកសុំកងទ័ព ក៏ជាប់នៅក្នុងស្រុកប៉ាក់ហៃដោយសេចក្ដីព្រួយទុក្ខជាមួយនឹងខុងយ៉ុង ។

លុះព្រឹកព្រាងឡើង ខុនយ៉ុងឡើងមើលលើសែនបន្ទាយ ឃើញពួកចោរព័ទ្ធជុំវិញ ខុនយ៉ុងក៏ប្រៀបប្រែងទាហានយាមល្បាតប្រយ័ត្នការជាមាំមួនណាស់ ។

ពេលនោះមានទាហានម្នាក់ជិះសេះពុះពារទំលាយកងទ័ពចោរ ចូលមកដល់ទ្វារស្រុកស្រែកឲ្យបើកទ្វារទទួល ។ ខុនយ៉ុងក្រឡេកឃើញមិនទាន់ហ៊ានបើកព្រោះមិនស្គាល់ច្បាស់ ។ ឯទាហានពួកចោរក៏តាមស្រូចូលមក ទាហានម្នាក់នោះក៏ត្រឡប់ទៅវិញ ដេញកាប់ពួកចោរស្លាប់ជាច្រើន ខុនយ៉ុងឃើញច្បាស់បង្គាប់ឲ្យបើកទ្វារទទួល ទាហាននោះក៏ចូលមក ខុនយ៉ុងសួរថា អ្នកឈ្មោះអ្វី? មកពីណា បានជាពុះពារទំលាយពួកចោរចូលមកបាន? ។ ថៃស៊ូជូលោតចុះពីលើសេះបោះខ្លួនពីដៃចេញ ហើយទូនគំនាប់ថាខ្ញុំបាទឈ្មោះថៃស៊ូជូ នៅស្រុកអ៊ុយគួនមាតាខ្ញុំបាទបានសរសើរដល់គុណលោកថា បានឲ្យអាវសំពត់នឹងបាយទឹកត្រីសាច់ដល់មាតាខ្ញុំមកពីដើម ឥឡូវនេះមាតាខ្ញុំបានដឹងព្រឹថា ពួកចោរមកចោមព័ទ្ធស្រុកលោករើបគាត់ប្រើខ្ញុំបាទឲ្យមកជួយច្បាំង ប្រាថ្នានឹងតបស្នងសងគុណ បានជាខ្ញុំបាទទំពុះពារទំលាយពួកចោរចូលមកនេះខ្ញុំបាទសម្លាប់អស់ពួកចោរជាច្រើន ។ ខុនយ៉ុងបានឮច្បាស់ក៏នឹករលឹកឃើញបាន ហើយតបថា "កាលអ្នកនៅពីតូចនោះ យើងសំគាល់ថានឹងមានសតិបញ្ញាគួរជាទាហានបាន បានជាយើងយករបស់ទៅឲ្យ

ដើម្បីចងជាមេត្រីទុកនឹងមាតារបស់អ្នក, ដែលមាតាប្រើអ្នកមកជួយធុរៈយើងគ្រានេះ យើងមានសេចក្ដីសោមនស្សត្រេកអរណាស់" និយាយហើយក៏យកក្រឹសនឹងអាវឲ្យ ។ ថៃស៊ីជួទទួលយកក្រឹសនឹងអាវដោយអំណរ ហើយគំនាប់ដំរាបថា ខ្ញុំបាទនឹងសុំទាហាន ១ ពាន់ លើកចេញទៅវាយពួកចោរត្រាតែបែកឲ្យបាន ។

ខុងយ៉ុងឃាត់ហាមថា ខុនអ្នកមានថ្វីដៃខ្លាំងពូកែមែនហើយ តែថាវេលានេះ ពួកចោរច្រើនខ្លាំងពូកែណាស់ ក្រែងអ្នកតទល់ពុំបាន ។ ថៃ-ស៊ីជួតបថា លោកមានគុណនឹងមាតាខ្ញុំបាទជាច្រើន ទោះបីខ្ញុំបាទនឹងស្លាប់ក្នុងកងទ័ពក៏ពុំស្ដាយជីវិត ខ្ញុំបាទគិតឲ្យបានតែតបគុណលោកដែលមានឧបការៈនឹងមាតាខ្ញុំបាទប៉ុណ្ណោះ បើខ្ញុំបាទត្រឡប់ទៅវិញហើយមាតាដឹងថាខ្ញុំបាទពុំបានធ្វើការអ្វីសោះ ទោសខ្ញុំបាទក៏មានច្រើន ។ ខុងយ៉ុងតបថា ត្រូវហើយ យើងចង់បានអ្នកទុកជាទីប្រឹក្សាទើបហាមឃាត់ដូច្នេះ ព្រោះទាហានអ្នកស្រុកយើងតិចណាស់ ឯឡៀវពីគេមានសតិប្បញ្ញាបានកួនអ៊ូ, តៀវហ៊ុយទុកជាកំឡាំង បើបានឡៀវពីមកជួយច្បាំងជាទ័ពសន្ធប់ ពួកទ័ពចោរក៏គង់នឹងបែកពុំខាន តែថានឹងរកអ្នកឯណាកាន់សំបុត្រទុះពារចំលាយទៅគ្មាន ។ ថៃស៊ីជួតបថា បើលោកមិនឲ្យខ្ញុំបាទចេញទៅច្បាំងទេ នឹងឲ្យខ្ញុំបាទនាំសំបុត្រទៅវិញ ខ្ញុំបាទនឹងនាំចេញទៅឲ្យឡៀវពី ។

ខុងយ៉ុងក៏តាំងធ្វើសំបុត្រជាសេចក្ដីថា "ខុងយ៉ុងចៅហ្វាយស្រុកប៉ាក់ហៃឲ្យពរមកដល់ឡៀវពីចៅហ្វាយស្រុកដេងង៉ួនកួន ដ្បិតវេលានេះកួន

ហៃ នាំពួកចោរកំណាចប្រែហៃលបួនប្រាំម៉ឺនមកឡោមព័ទ្ធខែត្រខ្ញុំជុំវិញ អ្នកប្រមាទចិត្តគិតមេត្តាដល់ខ្ញុំ លើកទ័ពមកច្បាំងសម្លាប់ពួកចោរជាទ័ពខ្ញុំពីក្រៅឲ្យបាន ខ្ញុំនឹងអ្នកក៏នឹងមានផ្លូវមេត្រីនឹងគ្នាតទៅ" លុះធ្វើសំបុត្រហើយក៏ប្រគល់ឲ្យថៃស៊ីជូៗ ទទួលសំបុត្រភ្លាម ក៏ត្រៀមខ្លួនពាក់ក្រឹសជិះសេះ កាន់ទួនបរចេញតាមទ្វារស្រុកទៅដល់មុខបន្ទាយទ័ពចោរ ៗ ក្នុងហៃឃើញក៏លើកទាហានចេញស្រមកដេញចាប់ថៃស៊ីជូៗ ក៏បង្រែះពុះពារទ័ពចោរតនឹងអាវុធឥតរួញរា ពួកចោរពិការស្លាប់នឹងគណនាពុំបាន ៗ ថៃស៊ីជូបេះតែកាប់ក្ការប៉ពារផ្លុះផ្លាយទៅ លុះទៅដល់ស្រុកផេងផ្លូនកួនចូលទៅគំនាប់ឡៅតីហើយជូនសំបុត្រទៅឡៅតីមើល ៗ ឡៅតីដឹងក្នុងសេចក្ដីសំបុត្រនោះនៅមិនទាន់ឆ្លើយថាម្ដេច ក៏លួចសំឡឹងមើលរូបភាពថៃស៊ីជូ ឃើញមាំមួនសួនសមជាទាហានហើយសួរថា អ្នកឈ្មោះអ្វី? ថៃស៊ីជូឆ្លើយថា ខ្ញុំបាទឈ្មោះថៃស៊ីជូ នឹងបានជាញាតិសាលោហិតស្និទ្ធស្នាលនឹងខុងយ៉ុងក៏ទេ, ដែលខ្ញុំបាទទទួលយកអាសាមកនេះ ព្រោះខុងយ៉ុងមានគុណនឹងមាតាខ្ញុំបាទពីដើម ៗ ឡៅតីបានស្ដាប់ក៏ចាប់ចិត្តស្រឡាញ់ហើយសរសើរថៃស៊ីជូថា ជាអ្នកមានចិត្តកតញ្ញូនឹងមាតា ហើយសួរថា ដែលខុងយ៉ុងរកប់អានឲ្យមកសុំកងទ័ពយើងទៅជួយនោះ យើងមុខជានឹងលើកទៅតាមត្រូវការ ៗ ពេលនោះឡៅតីឲ្យក្វនអ៊ូ តៀវហ៊ុយប្រមូលសេនាទាហានបាន ៣ ពាន់ ហើយនាំថៃស៊ីជូលើកចេញទៅស្រុកប៉ាក់ហៃ ។

ឯកូនហៃនាយចោរ លុះឃើញកង់ទ័ពលើកមកពីក្រោយដឹងថាជាទ័ពលើកមកជួយខុនយ៉ុន ក៏ប្រៀបប្រចង់ទាហានឆាកទៅតទល់ ៗ ទ្បាពីបរពលចូលទៅជិតហើយ ឲ្យកូនអ៊ូ គៀវហ៊ុយ នឹងថៃស៊ួជួ បរសេះស្រូតទៅមុខទាហាន ។ កូនហៃក្រឡេកឃើញកង់ទ័ពដែលលើកមកនោះតិច ក៏ប្រមាថមើលងាយមិនសូវនឹងប្រឹងសង្គ្រាមប្រយ័ត្នការ បរសេះចេញទៅតសង្គ្រាមពីមុខទាហាន ។ ថៃស៊ួជួបរសេះបំពានចេញទៅទទួលឃើញកូនអ៊ូបរសេះស្ទុះលឿនទៅមុខខ្លួនក៏ទាញសេះទប់ ឯកូនអ៊ូចូលទៅសិប់តគ្នានឹងកូនហៃបាន ៣០ ស្ទៀត កូនអ៊ូយកដាវវែងកាប់ត្រូវកូនហៃដាច់ពាក់កណ្តាលខ្លួនធ្លាក់ពីលើសេះស្លាប់ ៗ កូនអ៊ូថៃស៊ួជួក៏ដេញកាប់ទ័ពចោរជាកោឡាហល ទ្បាពីនឹងគៀវហ៊ុយចូលច្របល់ពីក្រោយទៀត ៗ ឯខុនយ៉ុនបានឮសំឡេងកង់ទ័ពគឹកកងក៏ឡើងមើលសែនបន្ទាយ ឃើញកង់ទ័ពទ្បាពីដេញកាប់សម្លាប់ពួកចោរបែកបាក់ខ្ចាត់ខ្ចាយ ទុបមាដូចខ្យាដេញខាំហ្វូងប្រើសទ្រាយកណ្តាលត្រាញ់ ខុនយ៉ុនក៏មានសេចក្តីត្រេកអរពន់ប្រមាណស្ទុះទៅបរពលខ្លួនពីក្រោយ ពួកចោរបែកបាក់ស្លាប់ពីការខ្លះរត់រួច ខ្លះមកនៅនឹងទ្បាពី ៗ

ខុនយ៉ុនឲ្យអញ្ជើញទ្បាពី កូនអ៊ូ គៀវហ៊ុយនឹងថៃស៊ួជួ ចូលមកកង់ស្រុក ហើយរៀបតែងគ្រឿងភោជនាហារ ៗ កាលកំពុងបរិភោគខុនយ៉ុនឲ្យបុត្រក្រោកឡើងគំនាប់ទ្បាពី ហើយខុនយ៉ុនពណ៌នារឿង

ដែលគូកៀមប្រើចិត្តកការសំបុត្រមកសុំកងទ័ព ទៅជួយច្បាំងនឹងចូឆូ ទទួលកងទ័ពក្នុងហៃមេះបារមកឡោមព័ទ្ធចេញទៅពុំបានៗ ជាចិត្តក៏ទន់នៅក្នុងទីនេះ ៗ

ឡៀវពីតបថា គូកៀមជាមនុស្សពិតត្រង់ល្អណាស់, ដែលនឹងក្លែងកលឲ្យកើតហេតុទាំងនេះ ក៏គឺតែកម្មរបស់គូកៀមឯង ៗ ខុងយ៉ុងឆ្លើយថា ឥឡូវនេះចូឆូស្មានថា គូកៀមប្រើឧបាយ បានជានៅគុំគួន នឹងសងសឹកគូកៀមវិញ ឯកងទ័ពចូឆូលើកមកនោះច្រើនអនេកណាស់ ប្រទូសរ៉ាយដល់ពួកអ្នកស្រុកសិងវិនាសអស់ទាំងប្រុសស្រី ខ្លួនអ្នកជាពូជព្រះរាជវង្សព្រះចៅហៀនតេ គួរហើយនឹងទំនុកបំរុងឲ្យបណ្ដារាស្ត្រទាំងពួងមានសេចក្ដីសុខក្សេមក្សាន្ត ខ្ញុំសូមអញ្ជើញអ្នកលើកទ័ពទៅជាមួយនឹងខ្ញុំ ដើម្បីនឹងជួយគូកៀម ដែលចូឆូលើកទ័ពមកប្រទូសរ៉ាយនោះ ៗ ឡៀវពីបានស្ដាប់ឆ្លើយតបថា ដែលអ្នកនិយាយមកនេះគួរសមហើយ តែថាយើងខ្លាចក្រែងមិនដួនការព្រោះទាហានយើងតិចណាស់ បើនឹងលើកទៅតតាំងតង់នឹងបាញ់ចូឆូ ៗ ខុងយ៉ុងឆ្លើយថា ដែលខ្ញុំប៉ងនឹងលើកទ័ពទៅជួយគូកៀមនោះ មិនមែនព្រោះឃើញលាភសក្ការៈ ឬព្រោះគាប់ចិត្តអ្នកនោះក៏ទេ ចំពោះឃើញថាគូកៀមជាមនុស្សសុចរិតពិតត្រង់នឹងផែនដី មានសេចក្ដីមេត្តាអាណិតអាណាប្រជានុរាស្ត្រឲ្យនៅជាសុខ ដូចខ្លួនអ្នកជាពូជព្រះរាជវង្សព្រះចៅហៀនតេ យល់ឃើញថានរណាជា

មនុស្សកតញ្ញូនឹងផែនដីហើយមានទុក្ខធុរៈពិត គួរនឹងជួយអាណិតប្កលះ ចិត្តមិនរវល់វិញ? ។

ទៀតពីតបថា ចិត្តរបស់ខ្ញុំដែលបានដឹងក្ដីដូច្នេះនឹងបានកន្តើយព្រងើយក៏ទេ តែវេលានេះសុំឲ្យអ្នកលើកទាហានទៅមុនចុះ ខ្ញុំនឹងវិលទៅរឹតទាហានកងស៊ុនចានឲ្យបាន ២-៣ ពាន់ផ្សំគ្នា ហើយលើកតាមអ្នកទៅជាក្រោយ ។ ខុងយ៉ុងឆ្លើយថា ដែលអ្នកនឹងលើកទៅតាមក្រោយនោះកុំឲ្យបញ្ឆោតយើង ។ ទៀតពីតបថា "អ្នកដែលដឹងក្ដីគេនិយាយថាខ្ញុំធ្លាប់បញ្ឆោតកូតករអ្នកណាខ្លះ? បើយើងទៅរឹតទាហានគេបានក្ដីមិនបានក្ដី យើងក៏លើកទៅតាមអ្នកជាប្រាកដ" ហើយក៏លាខុងយ៉ុងត្រឡប់ទៅរកកងស៊ុនចាននៅស្រុកប៉ាក់ប៉េង ។ ខុងយ៉ុងក៏ឲ្យបិតុកស្រូតទៅប្រាប់គូកៀមថា នឹងលើកទ័ពទៅជួយ, បិតុកទទួលពាក្យហើយលាខុងយ៉ុងត្រឡប់ទៅ ។

ខណៈនោះមានមនុស្សមកប្រាប់ថៃស៊ូជូថា ឡេវអ៊ីវឲ្យហៅទៅជួប ។ ថៃស៊ូជូចូលទៅជំរាបខុងយ៉ុងថា ដែលមាតាខ្ញុំបាទប្រើឲ្យមកតបស្នងសងគុណលោកនោះ ខ្ញុំបាទក៏បានធ្វើការសម្រេចហើយ ឥឡូវនេះឡេវអ៊ីវចៅហ្វាយស្រុកអៀងជីវ ប្រើបំរើឲ្យនាំសំបុត្រមកហៅខ្ញុំបាទថាឲ្យទៅដើម្បីនឹងប្រឹក្សាការរាជការ បើខ្ញុំបាទមិនទៅទេនឹងខូចផ្លូវមេត្រីរាប់អានគ្នា ហេតុនេះខ្ញុំបាទសូមលាលោកទៅសិន ។ ខុងយ៉ុងបានស្ដាប់ក៏ចាប់

ចិត្តអាល័យថៃស៊ូជូណាស់ ទើបចូលទៅយកមាសប្រាក់ នឹងសំពត់អាវឲ្យជាគំនាប់ថៃស៊ូជូ ៗ ថារបស់ទាំងនេះសូមលោកទុកចែកចាយឲ្យទាហានចុះ ហើយលាខុងយ៉ុងទៅរកមាតា ពណ៌នាប្រាប់សេចក្ដីឲ្យមាតាស្ដាប់គ្រប់ប្រការ ។ មាតាបានស្ដាប់មានសេចក្ដីសោមនស្សណាស់ទើបថាដែលឡៀវអ៊ីវចៅហ្វាយស្រុកអៀងជីវឲ្យមករកកូននោះចូរទៅជាប្រញាប់ចុះ ៗ ថៃស៊ូជូលាមាតាចេញទៅដល់ស្រុកអៀងជីវ ។

ឯឡៀវពីកាលទៅដល់ស្រុកប៉ាក់ចេង ចូលទៅរកកុងស៊ុនចានជួបហើយនិយាយថា ឥឡូវនេះចូចូលើកទ័ពទៅច្បាំងនឹងតូកៀមចៅហ្វាយស្រុកឈីជីវ, ខ្ញុំមកសុំខ្ចីទាហានអ្នក ២ - ៣ ពាន់ ដើម្បីលើកទៅជួយតូកៀមធ្វើសង្គ្រាមតនឹងចូចូ ៗ កុងស៊ុនចានបានស្ដាប់ឆ្លើយតបថា ចូចូហើយនឹងអ្នកមិនជាទោសទាស់គ្នាពីស្អីសោះ អ្នកនឹងលើកទៅជួយខាងតូកៀមនោះ ខ្ញុំមិនយល់ព្រមផងទេ ៗ ឡៀវពីតបថា ខ្ញុំបានទទួលពាក្យនឹងខុងយ៉ុងទៅហើយ បើត្រឡប់ជាមិនទៅវិញ ខុងយ៉ុងនឹងថាខ្ញុំចរចាមិនពិត ៗ កុងស៊ុនចានឆ្លើយថា បើអ្នកបានជាទទួលពាក្យគេមកហើយខ្ញុំនឹងឲ្យទាហានសេះតែត្រឹម ២ ពាន់ចុះ ៗ ឡៀវពីតបថា ខ្ញុំនឹងសុំជូឡុងទៅផង ៗ កុងស៊ុនចានក៏ព្រមឲ្យ ៗ ឡៀវពីមានសេចក្ដីត្រេកអរណាស់ទើបនាំយកជូឡុងនឹងទាហានកុងស៊ុនចានចំនួន ២ ពាន់ ឲ្យជូឡុងជាកងទ័ពក្រោយ ៗ

(មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យឧករដំ

## អ្នកឧកញ៉ាទេពពិទូរ ឈឹម - ក្រសេម រៀបរៀង

(តមក)

---

តាំងពីឆ្នាំ ព. ស. ១៧៣៣ ដល់ ព. ស. ១៧៦៣ ប្រទេសចាម្ប៍ បានធ្លាក់មកជាសម្បត្តិរបស់ប្រទេសកម្ពុជា ដោយស្នាព្រះហស្តរបស់ព្រះបាទជយវរ្ម័នទី ៧ ។ តែការដែលទ្រង់តាំងព្រះវិទ្យានន្ទន៍ឲ្យនៅគ្រងខែត្របណ្ឌុរង្គនោះ ទុកជាដ្គងក្នុងផ្ទៃរដ្ឋប្បសាសនោបាយ ព្រោះការដែលចាប់កពស់វែកមិនខ្ជាប់ រមែងត្រឡប់ខាំឯប្រាណវិញ ឬថាអ្នកជឿទុកចិត្តសត្វសាហាវ ច្រើនតែបានទទួលទោសទុក្ខស្នងមកវិញ ។ រឿងព្រះវិទ្យានន្ទន៍ ក៏មិនល្អៀងពីសំដីនេះ ទោះបីព្រះបាទជយវរ្ម័នទ្រង់ចិញ្ចឹមតាំងពីតូច ទ្រង់បង្ហាត់បង្រៀនវិទ្យាសាស្ត្រនិងយុទ្ធសាស្ត្រ ទ្រង់ព្រះរាជទានយសជា យុវរាជ ព្រមទាំងគ្រឿងសប្បាយគ្រប់យ៉ាង រហូតដល់ទៅឲ្យគ្រងស្រុកធំ ១ ក៏នៅតែមិនស្កប់ចិត្ត ឬមិនសាំងទៀត ។ ក្នុងឆ្នាំ គ. ស. ១២០៣ ពួកចាម្ប៍បានបង្កហេតុបះបោរ បណ្ដេញព្រះមហាឧបរាជខ្មែរចេញពីក្រុងវិជ័យ ។ ព្រះវិទ្យានន្ទន៍ឃើញបានឱកាសក៏ស្រវាត្រួតត្រាប្រទេសចាម្ប៍ទាំងមូល ដោយមិនបានទទួលព្រះរាជានុញ្ញាត

នុញ្ញាតពីព្រះបាទជយវរ្ម័នជាអម្ចាស់របស់ខ្លួន ។ ព្រះបាទជយវរ្ម័នទី ៧ កាលទ្រង់ផ្ចាញ់ផ្ចាលបះបោរនោះហើយ ទើបត្រាស់ចាត់ឲ្យព្រះជយ-ឥន្ទ្រវរ្ម័ន (ក្សត្រិយ៍ឈ្វើយ) ចេញទៅកម្ចាប តែកាលទៅដល់ក្រុង វិជ័យ ក៏ត្រូវព្រះវិទ្យានន្ទន៍ធ្វើគត់បង់ ។ ព្រះមហាក្សត្រិយ៍មិនព្រម លះលែងចាម្ប៉ាទើបទ្រង់ស្ដួកស្ដេចចាម្ប៉ា ១ អង្គ សឹងត្រូវជាបិតុលៈរបស់ព្រះវិទ្យានន្ទន៍ឲ្យដេញព្រះវិទ្យានន្ទន៍ចេញពីប្រទេសចាម្ប៉ា ។ តាំងពីឆ្នាំ គ. ស. ១២០៣ ដល់ ១២២០ ប្រទេសចាម្ប៉ាទុកដូចជាខែត្រ ១ របស់ប្រទេសកម្ពុជា ព្រោះទ្រង់មិនតាំងក្សត្រិយ៍ចាម្ប៉ាឲ្យគ្រប់គ្រងដូចមុនៗ ។

ក្រោយដែលកម្ចាបចាម្ប៉ាបរាជ័យហើយ ព្រះបាទជយវរ្ម័នបាន ស្ដេចលើកទ័ពទៅកម្ចាបប្រទេសផ្សេងៗ ប៉ែកខាងលិចនិងខាងជើង ។ តាមសិលាចារឹកខ្មែរ ១ នៅសាយហ្វុង មុខក្រុងវៀងចន្ទន៍ និងប្រវត្ត-សាស្ត្ររបស់ចិន ១ នាក់ទៀតថា ព្រះបាទជយវរ្ម័នបានស្ដេចលើកទ័ពទៅត្រួតបច្ចូនដែនម៉ាលយូ ១ ភាគ ប៉ែកខាងឆាយដែលធ្លាប់ជាអាណានិគមរបស់ខ្មែរតាំងអំពីដើមរៀងមក ទ្រង់បានរៀបចំការគ្រប់គ្រង ឲ្យអនុវត្តន៍ទៅតាមប្រវេណីដើម គឺឲ្យមានព្រះឧបរាជឈរគ្រប់គ្រង នៅក្រោមឥទ្ធិពលខ្មែរតមក ។

លំដាប់អំពីនោះ បានស្ដេចលើកទ័ពទៅកម្ចាបប្រទេសភូមាដែល ជាប្រទេសធ្លាប់នៅក្រោមអំណាចខ្មែរដែរ តែក្នុងពេលមុននេះ ប្រទេស

កម្ពុជាបានធ្វើសឹកជាមួយប្រទេសចាម្ប៉ាជាញឹកញយ ប្រហែលជាពួកនេះឃើញបានឱកាស ក៏ប្រកាសតាំងខ្លួនជាឯករាជ្យឡើង ទើបព្រះបាទជយវរ្ម័នលើកទ័ពហ្លួងទៅក្រាប ហើយទ្រង់បានតាំងក្សត្រិយ៍ភូមាឲ្យនៅគ្រប់គ្រងជាប្រទេសរាជ ។

តអំពីនោះ បានស្ដេចលើកទ័ពចេញទៅត្រួតបន្ទូរដ្ឋប៉ែកខាងជើងគឺតាំងពីវៀងចន្ទន៍ ហ្លួងព្រះបាង រហូតទៅទល់ប្រទេសចិន ហើយទ្រង់បានតាំងព្រះរាជវង្ស ១ អង្គព្រះនាម "រាជេន្ទ្រវរ្ម័ន" ជាឧបរាជនៅគ្រប់គ្រងរដ្ឋនេះ ។ វេលានោះ ព្រះរាជេន្ទ្រវរ្ម័ន ប្រហែលជាតាំងរាជធានីនៅវៀងចន្ទន៍ ។

តាមដែលបានពោលមកនេះ ឃើញថា ព្រំប្រទល់នៃព្រះរាជអាណាចក្រកម្ពុជា ក្នុងរដ្ឋកាលព្រះបាទជ័យវរ្ម័ន ទី ៧ នោះធំទូលាយ មានបរិមាណប្រហែលគ្នានឹងរដ្ឋកាល ព្រះសូរ្យវរ្ម័ន ទី ២ គឺ :

ខាងកើត រួមប្រទេសចម្ប៉ាចូលមកផង ;

ខាងត្បូង ដល់សមុទ្រប៉ាស៊ីហ្វិគ ;

ខាងនិរតី ដល់ពាក់កណ្ដាលប្រទេសម៉ាលយូ ;

ខាងលិច ដល់ប្រទេសភូមា ;

ខាងជើង ទល់ប្រទេសចិន ។

ក្នុងកាលក្រោយ ដែលទ្រង់កម្រាបខឹងរៀបចំរដ្ឋបាលនេះហើយ មរណទុក្ខយ៉ាងធ្ងន់ បានធ្លាក់មកត្រូវព្រះអង្គ គឺព្រះនាងជយរាជទេវី អគ្គមហេសីរបស់ព្រះអង្គ សោយព្រះពិរាល័យចាកចោលព្រះអង្គទៅ ។ ក្រោយនោះ ទ្រង់បានឲ្យធ្វើព្រះរាជពិធីអភិសេក ព្រះនាងឥន្ទ្រទេវី សឹងត្រូវជាព្រះជេដ្ឋភគិនីរបស់ព្រះនាងជយរាជទេវី ឲ្យឡើងជា ព្រះអគ្គមហេសីតមក តែព្រះនាងនេះ គ្មានព្រះរាជឱរស ឬព្រះរាជធីតាទេ ។

## ព្រះគុណសម្បត្តិនៃព្រះនាងឥន្ទ្រទេវី

ព្រះនាងឥន្ទ្រទេវី ទ្រង់បានសិក្សាអក្សរសាស្ត្ររបស់ជាតិ នឹងអក្សរសាស្ត្រភាសាសំស្ក្រឹត ទាំងទ្រង់បានសិក្សាគតិធម៌ក្នុងព្រះពុទ្ធសាសនា ។ ប្រាកដក្នុងសិលាចារឹកថា ព្រះនាងនេះ ពូកែលើសលប់គ្មានអ្នកណាស្មើបានក្នុងវិជ្ជាសាស្ត្រនឹងបរមត្ថ , ព្រះមហាក្សត្រិយ៍ទ្រង់បានតាំងព្រះនាងជា បរិនាយកាចារ្យ បង្ហាត់បង្រៀនសិស្សទាំងឡាយនៅក្នុងវត្តព្រះពុទ្ធសាសនា ។ សិលាចារឹកនៅវិមានអាកាសក្នុងមហានគរសំដែងថា: ព្រះនាងគង់នៅក្នុងអាពម ១ ឈ្មោះ នរេន្ទ្រាស្រម(១) ជាទីធំនៃការសិក្សា ។ ព្រះនាងបានបង្ហាត់បង្រៀនពួកស្ត្រី នឹងកុមារីរាជបរិពារជាយ៉ាងច្រើន រាល់ៗថ្ងៃ; មានអ្នកបេះដូងតាមព្រះនាងច្រើនអនេក សូម្បី

១ មានប្រាប់នៅទីដទៃទៀតថា ព្រះនាងជាគ្រូបង្រៀននៅនរេន្ទ្រាស្រម, នាគេន្ទ្រ នឹងតិលកោត្តរ ជា ៣ កន្លែង ។

ព្រះនាងជយរាជទេវី ក៏បានសិក្សាក្នុងសំណាក់ព្រះនាងដែរ ។ ព្រះនាងក៏ល្បីព្រះកិត្តិយស នឹងជាទីគោរពរបស់សិស្សទាំងឡាយ, ព្រះនាងជាអ្នកធ្វើឲ្យសិស្សស្ត្រីអំបាលនោះ បានទទួលនូវសេចក្ដីសុខ ហាក់ដូចជាទេពធីតាឈ្មោះ សរស្វតី បែងភាគមកស្រោចស្រង់ ។ ការដែលព្រះនាងបង្ហាត់បង្រៀនទាំងប៉ុន្មាន ឧបមាដូចជាទឹកទិព្យដ៏ប្រសើរដែលបង្ហូរចេញមកជាសេចក្ដីចេះដឹងយ៉ាងជ្រាលជ្រៅ. ព្រះនាងមានព្រះរាជហឫទ័យដេកដួលខ្ជាប់នៅក្នុងផ្លូវធម៌អាថ៌ ។ សូម្បីព្រះនាងបានជាអគ្គមហេសីក៏មិនវង្វេងទៅតាមយសសក្ដិនេះ ។ តែព្រះពុទ្ធសាសនាដែលព្រះនាងទទួលប្រព្រឹត្តប្រតិបត្តិនេះ គឺជាលទ្ធិមហាយាន ។ ឯភាសាសំស្ក្រឹតគេសង្កេតឃើញថា ព្រះនាងមានសេចក្ដីចេះដឹងយ៉ាងជ្រាលជ្រៅពិតប្រាកដ ដោយមានសិលាចារឹកយ៉ាងធំ នៅវិមានអាកាសជាស្នាព្រះហស្តដែលព្រះនាងចារឹកទុក ។

**ការព្រះសាសនានិងការកសាង** – ព្រះបាទជយវរ្ម័នក្រោយដែលទ្រង់បានរៀបចំការផែនដីឲ្យបានធំទូលាយ នឹងសាន្តត្រាណរៀបរយហើយ ទ្រង់ក៏ចាប់ផ្ដើមការកសាងយ៉ាងសំបើម ។ ដំបូងទ្រង់បានបដិ-សង្ខរណៈក្រុងយសោធរបុរៈ ( នគរធំ ) គឺសាងកំពែងនឹងគូជុំវិញកំពែងជាថ្មី ឲ្យមាំមួននឹងធំទូលាយចេញទៅ ។ តាមហាត់ជោថ្មីនេះទុកប្រាសាទបាយ័នជាកណ្ដាលក្រុង មានមាត់ទ្វារនៅកំពែងក្រៅ ៥ អន្ទ្រ គឺទិស

ខាងកើតពីរ ទិសក្រៅពីនេះមួយៗ ។ កំពែងនោះវាស់ដោយជុំវិញចំនួន ១២ គីឡូម៉ែត្រ ។ វាស់ដោយសន្មត់ជា ៤ ជ្រុងចតុរស (គឺបណ្តោយ ៣ គីឡូម៉ែត្រ ទទឹង ៣ គីឡូម៉ែត្រ, ទ្រង់ឲ្យឈ្មោះកំពែងនេះថា "ជយគិរី" ឲ្យឈ្មោះគូរជុំវិញកំពែងថា "ជយសិន្ធុ" តែសព្វថ្ងៃនេះអ្នកសៀមរាបហៅថា "កសិន" ល្អៀងចេញពីឈ្មោះដែលពិត ។

ប្រាសាទកណ្តាលក្រុង តាមសិលាចារិកឃើញឈ្មោះ "ភ្នំកណ្តាល" ក៏មាន ហៅ "យសោធរគិរី" ក៏មាន ។ ប្រាសាទនេះគេសង្កេតឃើញថា មានការបដិសង្ខរណៈជាច្រើនលើក តែមានបញ្ហាថា ក្សត្រិយ៍អង្គណាជាអ្នកសាងជាដំបូង? ។ តាមយោបល់របស់អ្នកប្រាជ្ញទាំងឡាយដែលបានពិនិត្យនឹងស្រាវជ្រាវកន្លងបច្ចុប្បន្ននេះបែកគ្នាជា ២ ន័យគឺ អ្នកខ្លះថាសាងតាំងពីកន្លងរជ្ជកាលព្រះបាទយសោវរ្ម័ន; អ្នកខ្លះថា ព្រះបាទជយវរ្ម័នទី ៧ ទ្រង់សាងឡើង ដោយអាងថា "នៅប្រាសាទនេះត្រង់ជ្រុងក្ពូសានមានរូបព្រះពោធិសត្វលោកេស្វរៈ ១ ជាសំគាល់ ព្រោះថាព្រះបាទជយវរ្ម័នទី ៧ ទ្រង់រាប់អានព្រះពុទ្ធសាសនាលទ្ធិមហាយាន កាលទ្រង់សាងប្រាសាទនេះឡើង ទើបឲ្យសាងរូបព្រះពោធិសត្វនេះ; ឯព្រះបាទយសោវរ្ម័នទ្រង់រាប់អានសាសនាព្រាហ្មណ៍ គង់ជាមិនសាងរូបក្នុងព្រះពុទ្ធសាសនា" ។

( មានត )

ពិធីបុណ្យប្រគេនព្រហ្មទាន

ចំពោះព្រះសង្ឃ ៨៨ រូបដែលប្រឡងជាប់សញ្ញាប័ត្រ

សាលាបាលីជាន់ខ្ពស់

# ផ្សាយពីសមាគមមិត្តសាលាបាលី

តនឹងចប់

---

សុន្ទរកថា

## ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់

សូត្រក្នុងឱកាសប្រគេនព្រហ្មទេយ្យដល់សិស្សសាលាបាលីជាន់ខ្ពស់

នៅថ្ងៃទី ២៥ កម្ភៈ ១៩៥១

សូមថ្វាយព្រះពរព្រះករុណាជាម្ចាស់ជីវិត !

សូមថ្វាយបង្គំសម្តេច !

ថ្វាយព្រះពរ, ចំរើនពរ ចំពោះទ្រង់,

ឯកឧត្តម, ព្រះតេជព្រះគុណ,

នឹងអស់លោក - អ្នកទាំងឡាយ !

អម្បាញ់មិញនេះ លោកអធិបតីនៃសមាគមមិត្តសាលាបាលីបាន ថ្លែងសេចក្តីថ្វាយព្រះករុណាជាម្ចាស់ជីវិតរួចហើយ អំពីកិច្ចការដ៏ប្រសើរ ដែលសមាគមបានធ្វើ ចំពោះសាលាបាលីជាន់ខ្ពស់ ដែលជាមន្ទីរសិក្សាវិជ្ជាផ្នែកមួយក្នុងព្រះពុទ្ធសាសនា ប្រកបដោយសេចក្តីប្រៀបធៀប គួរឲ្យពុទ្ធសាសនិកជនទាំងឡាយមានសេចក្តីពេញចិត្តដោយច្រើន ៗ

ខ្ញុំនេះ អាត្មាភាពតាងនាមសាលាបាលីជាន់ខ្ពស់ សូមសំដែងសេចក្ដីកោតយដ៏លើសលប់ដោយគោរព ចំពោះព្រះករុណា ជាម្ចាស់ជីវិត ដែលទ្រង់ស្ដេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីចែកព្រហ្មទេយ្យ ដែលជាបុណ្យផ្ទៃកមួយ អាចជួយអប់រំកម្លាំងការសិក្សាក្នុងព្រះពុទ្ធសាសនា នាសាលានេះ ព្រោះពិធីបុណ្យមានសភាពដូច្នេះនេះ ជាសិរីសួស្ដីហើយជាកិត្តិយសដ៏ឧត្ដម ដល់សាលាបាលីជាន់ខ្ពស់ ក្នុងបច្ចុប្បន្ននេះនឹងតទៅអនាគត ។

ម្យ៉ាងទៀត សាលាបាលីជាន់ខ្ពស់ សូមទទួលអំណរយ៉ាងក្រៃលែង ចំពោះសមាគមមិត្រសាលាបាលី ដែលបាននាំផ្ដើមបាត់ចែងធ្វើកល្យាណ-កិច្ចគឺការចែករង្វាន់នេះជាកិច្ចគួរឲ្យសរសើរ ព្រោះតាំងពីថ្ងៃដែលសាលាបាលីជាន់ខ្ពស់នេះកើតឡើង មានអាយុ ៣៦ ឆ្នាំហើយ, ពិធីចែករង្វាន់ចំពោះសិស្ស ដែលបានប្រឡងចេញពីសាលាមានសភាពដូច្នេះ ទើបនឹងមានត្រឹម ៣ ដងប៉ុណ្ណោះ គឺពីក្នុង គ.ស. ១៩៤២ ពុទ្ធិកសមាគមកម្ពុជរដ្ឋ បានបាត់ចែងធ្វើពិធីចែករង្វាន់មួង, កន្លងពីនោះមក ៨ ឆ្នាំ គឺក្នុង គ.ស. ១៩៥០ សមាគមមិត្រសាលាបាលីបានបាត់ចែងផ្ដើមឯទៀតជាលើកទីពីរ, ដល់មកក្នុង គ.ស. ១៩៥១ គឺក្នុងពេលនេះសមាគមដដែលបានបាត់ចែងផ្ដើមឯទៀត ជាលើកទី ៣ ។ សមាគមដែលបានបំពេញកិច្ចដ៏ប្រសើរដូចខាងលើនេះ ជាហេតុនាំឲ្យកើតប្រយោជន៍ច្រើនយ៉ាងគឺ :

១ — នឹងនាំឲ្យចិត្តរបស់សិស្សដែលទើបនឹងប្រឡងជាប់ មានបីតិប្រាមោជ្ជគ្រប់រូប ហើយនឹងបានជាបច្ច័យនាំឲ្យសិស្សទាំងនោះខំអប់រំបំណេះវិជ្ជាឲ្យបានកើនចម្រើនទៅមុខទៀត ។

២ — សិស្សក្នុងសាលាគ្រប់ថ្នាក់ក្នុងបច្ចុប្បន្នទាំងក្នុងអនាគត នឹងសង្វាតឧហាតរៀនសូត្រជាកិរិយាភាពដោយឥតប្រហែសធ្វេស ដោយសំគាល់ជឿជាក់ក្នុងចិត្តថា ពុទ្ធបរិស័ទទាំងឡាយមានសេចក្តីជ្រះថ្លាអបអរសាទរជាច្រើន ចំពោះការរៀនសូត្រព្រះបរិយត្តិធម៌ ដោយយល់ថាការសិក្សាព្រះបរិយត្តិធម៌ជាកម្លាំង ១ ផ្នែក ក្នុងការដឹកនាំសាធារណជនឲ្យពេញចិត្តកើតសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបាន ។

៣ — នឹងបានជាទិដ្ឋានុគតិ គឺជាតម្រាប់តម្រាយជាផ្លូវសម្រាប់ពុទ្ធសាសនិកជនដើរតាមទៅក្នុងអនាគត ។

ក្នុងឱកាសដ៏ប្រសើរនេះ, សាលាបាលីជាន់ខ្ពស់ សូមព្រះរាជទានអភ័យទោស សូមព្រះរាជទានឱកាសថ្លែងសេចក្តីក្រើនរំពឹកប្រស្រ័យចំពោះព្រះសង្ឃជាសិស្សនៃសាលាបាលីជាន់ខ្ពស់ ដើម្បីទុកជាអនុស្សាវរីយ៍របស់សិស្សតទៅក្នុងអនាគត ។

អស់លោកជាសិស្សទាំងឡាយ !

អស់លោកដែលបានប្រឡងចេញពីសាលា ហើយបានទទួលនូវលទ្ធផលសមដូចបំណងនេះ ទុកជាចប់អស់ករណីយកិច្ចរបស់លោកគ្រប់រូប

ក្នុងសាលានេះហើយ ។ សេចក្ដីសម្រេចសមតាមប្រាថ្នានេះឯង គឺជាផលនៃសេចក្ដីប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀនសូត្ររាង ៤ ឆ្នាំ ដោយឥតមានប្រហែសធ្វេស ។ ប៉ុន្តែលោកទាំងឡាយកុំភ័ន្តច្រឡំសំគាល់ថា "ការសិក្សារបស់អាត្មាចប់ហើយត្រឹមបានទទួលសញ្ញាប័ត្រនេះ ហើយបោះបង់ការសិក្សាចោលលែងរវល់តទៅទៀត" ដូច្នេះឡើយ ព្រោះការសិក្សាក្នុងសាលាចំនួន ៤ ឆ្នាំនេះ គ្រាន់តែជាគ្រឿងដឹកមុខពន្យល់ឲ្យស្គាល់ផ្លូវដែលត្រូវដើរទៅមុខទៀតប៉ុណ្ណោះទេ នៅមានករណីយកិច្ចបន្ទាប់ពីនេះទៅទៀតច្រើនណាស់ ដែលជាមធ្យោបាយសម្រាប់ធ្វើការចេះដឹងឲ្យបានរីកធំទូលាយឡើង មធ្យោបាយនោះគឺការយកចិត្តទុកដាក់ក្នុងការត្រិះរិះពិនិត្យពិចារណា ស្រាវជ្រាវរកហេតុផលនៃវិជ្ជាចំពោះខ្លួនឯងតទៅទៀត ។

ម្យ៉ាងទៀត, ចំណេះវិជ្ជាដែលអស់លោកបានសិក្សារៀនសូត្របានសម្រេចដូចប្រាថ្នាពិតមែនហើយ ប៉ុន្តែបើអស់លោកមិនគិតស្វែងរកធម៌ជាបរិក្ខារមកជួយអប់រំ ជួយទប់ទល់ផងទេ ចំណេះវិជ្ជានោះនឹងលើកស្ទួយខ្លួនលោកឲ្យឋិតនៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់ គួរឲ្យគេគោរពរាប់អាន ក៏ពុំបានដែរ ។ សេចក្ដីសំខាន់ក្នុងរឿងនេះ បានដល់អាចារសីល ពោលគឺគំនិតមារយាទ ឬសណ្ដាប់ធ្នាប់ដ៏សមរម្យនោះឯង ។ អស់លោកគង់បានដឹងហើយថា មនុស្សយើងទោះបីចេះដឹងច្រើនអម្បាលម៉ានក៏ដោយ តែបើ

ខ្លះអាចារសីល គឺកិរិយាមារយាទដ៏ថ្លៃថ្លាហើយ មុខជានឹងទប់ខ្លួនឲ្យឋិតនៅជាស្ថាពរ ឬនឹងកែខ្លួនឲ្យទៅជាមានតម្លៃថ្លៃថ្នូរសមរម្យ តាមចំណេះនោះពុំបានឡើយ នឹងនាំឲ្យអាប់ឱន (ថោកថយសាបរលាប) ជាងមនុស្សសាមញ្ញទៅទៀតក៏សឹងមានដែរ ដូចពាក្យបុរាណលោកពោលទុកថា "អង្ករសស្អុំ បំអិនឲ្យឆៅ ពិសីហើយខ្លៅ ប្រាជ្ញាឥតមារយាទ" ។ អាចារសីល គឺកិរិយាមារយាទ សណ្ដាប់ធ្នាប់ដ៏ល្អនេះ ទុកជាទឹកនឹងដីជាតិ សម្រាប់ស្រោចស្រង់ចំណេះវិជ្ជា កុំឲ្យស្វិតស្រពោន ឲ្យបានលូតលាស់ជានិច្ច ឲ្យបានដុះដាលចម្រើនឡើងដោយប្រពៃ; ពុំនោះសោតទុកដូចជាកាជនៈដ៏មាំមួន សម្រាប់ដាក់ចំណេះវិជ្ជាឲ្យបានគង់នៅ កុំឲ្យធ្លាក់កក់កាយក៏បាន ។ គម្ពីរជាតក ខុទ្ទកនិកាយ លោកបានបែងទុកមកដោយការចាត់យកអាចារសីល គឺកិរិយាមារយាទជាថ្នាក់ទី ១ ថាបុគ្គលដែលនឹងតាំងខ្លួនជាមេជាបា ត្រួតត្រាគ្រប់គ្រងវង្សត្រកូលពួកក្រុម ឬសិស្សគណឲ្យបានសេចក្ដីសុខក្សេមក្សាន្ត ទូលំទូលាយទៅបាននោះ គោរងអាស្រ័យធម៌ ៣ ប្រការ គឺ:

១ - អាចារសីល = កិរិយាមារយាទល្អ,

២ - បញ្ញា = សេចក្ដីដឹងកិច្ចការសព្វអន្លើ ព្រមទាំងការវែកញែកវៀរវាស,

៣- ពាហុសច្ច = ការរៀនសូត្របេះដឹងច្រើន ។

ដូច្នេះ, អស់លោកគ្រប់រូបត្រូវស្ទួនគ្រងកិរិយាមារយាទឲ្យពេញថែមទៀត គឺត្រូវហាត់ កាយ វាចា ចិត្ត ឲ្យបានចុះបែបបទសមរម្យ ឲ្យស្របគ្នាទៅតាមបញ្ញានិងពាហុស្សុតៈ ដែលអស់លោកបានសន្សំរៀបមកហើយ នោះទើបបានឈ្មោះថាជាបណ្ឌិតជាតិ ពេញលក្ខណៈដែលអស់លោកត្រូវទទួលភារៈ ធ្វើការស្នងគ្រូអាចារ្យជាលំដាប់តទៅ ។

ម្យ៉ាងទៀត, ក្នុងសុន្ទរកថារបស់លោកអធិបតី នៃសមាគមមិត្តសាលាបាលីមានសេចក្ដីប្រៀបធៀបមួយអន្លើថា “ព្រះមហាក្សត្រទុកដូចជាមហាប្រថពី, សាលាបាលីជាន់ខ្ពស់ ទុកដូចជាព្រែកក្បាលតាជាតិ, ព្រះសង្ឃជាសិស្សទុកដូចជាបុប្ផាមានក្លិនក្រអូប, ទាយកទាយិកា ទុកដូចជាភមរជាតិគឺឃ្មុំបុកទូង ដែលតែងតែក្រេបយកលំអងកេសរនៃបុប្ផាទាំងនោះឯង” ។ ពាក្យនេះ អស់លោកទាំងអស់ក៏បានស្ដាប់យល់សេចក្ដីជាក់លាក់ហើយ គឺលោកជាសិស្សគ្រប់រូបទុកដូចជាផ្កាយ៉ាងវិសេសដែលបរិបូណ៌ដោយក្លិនក្រអូបនិងលំអងកេសរ ។ តាមអត្ថបទនេះត្រូវអស់លោកទាំងឡាយ ដំកល់ខ្លួននៅក្នុងអប្បមាទធម៌ ហើយទុកដាក់ខ្លួនក្នុងឋានៈយ៉ាងណាឲ្យសមរម្យជាផ្កាក្រអូបប្រកបដោយលំអងកេសរ អស់កាលជានិច្ចតទៅ គ្រាន់បានភមរជាតិគឺឧបាសកឧបាសិកា ចូលមកប្រស្រ័យទទួលយកនូវជារសផង ។

ដូច្នេះ សុំឲ្យអស់លោកជាសិស្សគ្រប់រូប គិតហើយគិតទៀត ពិចារណាហើយពិចារណាទៀត ហើយត្រូវរាំងប្រយ័ត្នកុំឲ្យខ្លួនអស់

លោកដែលប្រៀបដូចផ្កាមានក្លិនក្រអូបក្លាយទៅជាផ្កាចារផ្ការលួសដែល មានតែពណ៌ឥតក្លិននោះឡើយ ។

ក្នុងទីបំផុតនេះ សាលាបាលីជាន់ខ្ពស់ សូមឧទ្ទិសភាគផលនៃការសិក្សារៀនសូត្រព្រះបរិយត្តិធម៌ដែលភិក្ខុសាមណេរបានខំបំពេញមកដោយទឹកចិត្តដ៏បរិសុទ្ធអស់កាលជាយូរឆ្នាំមកហើយនោះ ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់បានប្រកបដោយសិរីសុវត្ថិមង្គលគ្រប់ប្រការ សូមទ្រង់បានប្រកបដោយព្រះជន្មាយុយឺនយូរក្នុងព្រះសិរីរាជសម្បត្តិអស់កាលជាអង្វែង! ទាំងសម្តេច ទ្រង់ ឯកឧត្តម ព្រះតេជព្រះគុណ នូវអស់លោក-អ្នក ដែលជាពុទ្ធបរិស័ទទូទៅក្នុងកម្ពុជរដ្ឋក៏សូមឲ្យបានប្រកបដោយសេចក្តីសុខ - ចំរើន អស់កាលជាអង្វែងតទៅ កុំបីអាក់ខានឡើយ! ។

## ព្រះរាជសុន្ទរកថា

# ក្នុងឱកាសពិធីប្រគេនព្រហ្មទាន

ដល់សិស្សសាលាបាលីជាន់ខ្ពស់ នៅថ្ងៃទី ២៥ ខែ កុម្ភៈ គ. ស. ១៩៥១

---

លោកគ្រូ!

អស់លោក!

ក្នុងឱកាសប្រគេនព្រហ្មទាននេះ ខ្ញុំករុណា - ខ្ញុំ មានសេចក្តីសោមនស្សពន់ពេកណាស់ ដោយបានមកជួយសរសើរព្រះសង្ឃជាសិស្សានុសិស្ស ដែលប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។

ខ្ញុំករុណា ខ្ញុំ បានដឹងថា ការរៀនយកសញ្ញាប័ត្រសាលាបរិយត្តិជាន់ខ្ពស់នេះ មិនមែនជាការងាយស្រួល គឺជាការខំអត់ធ្មត់សង្កត់ ដ៏ខ្ជាប់ខ្ជួនរៀនកបដកបមកជាច្រើនឆ្នាំហើយ ទើបបានសម្រេចផល ។ ដូច្នេះ ការប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់នេះ ជាការគួរឲ្យសរសើរណាស់ ។

ខ្ញុំព្រះករុណា - ខ្ញុំ សង្ឃឹមថាលោកដែលប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ដែលជនទាំងឡាយតែងសំគាល់លោកជាបណ្ឌិតទៅអនាគត ដោយលោកមានចំណេះវិជ្ជាដ៏ប្រពៃ ដើម្បីនឹងយកវិជ្ជានោះធ្វើឲ្យបានផលប្រយោជន៍ទៅច្រើនឡើងថែមទៀត ជាប្រយោជន៍ដល់ប្រទេសជាតិ ព្រមទាំងជាការតបស្នងសងគុណដល់ពួកពុទ្ធបរិស័ទទាំងឡាយ ដែលបានជួយឧបត្ថម្ភលោករៀនមក ក្នុងការរៀនសូត្រនេះនឹងយកព្រះទ័យទុកដាក់ណែនាំសិស្សានុសិស្ស និងឧបាសកឧបាសិកាក្នុងក្រុមលោករៀងរាល់ក្រុម ឲ្យបានចេះដឹងច្រើន និងប្រតិបត្តិកិរិយាឲ្យសមប្រកបតាមពុទ្ធសាសនោវាទ ជាប្រយោជន៍ខាងពុទ្ធចក្រនិងអាណាចក្រទៅ ។

ពិធីប្រគេនព្រហ្មទាននេះ ជាការមួយយ៉ាងសំខាន់ នាំឲ្យបណ្ដាជនានុជនច្រើនធាប់បានស្គាល់សិស្សានុសិស្ស ដែលរៀនសូត្រមានល្បីកេរ្តិ៍ឈ្មោះ ហើយនាំសំរើបទឹកចិត្តសិស្សានុសិស្ស ដែលចាប់រៀនឡើងពីដើមឆ្នាំកន្លងថ្នាក់នីមួយៗ ឲ្យខំរៀនប្រាថ្នាចង់បានសញ្ញាប័ត្រផង ប្រាថ្នាចង់បានកេរ្តិ៍ឈ្មោះផង ។

ដូច្នេះខ្ញុំករុណា - ខ្ញុំ សូមអរគុណដ៏ពន្លឹកដល់អស់លោក - អ្នកដែលបានចំណាយបច្ច័យជាកម្លាំងក្នុងការរៀបចំធ្វើពិធីប្រគេនព្រហ្មទាននេះជាយ៉ាងអនេក ។

លុះចប់ព្រះរាជសុន្ទរកថានេះហើយមហាជនបានទះដៃទទួល ព្រះរាជអំណារ, ទើបព្រះសង្ឃសូត្រជយន្តោទឹងមង្គលទាំងពួង ជាកិច្ចបង្ហើយបុណ្យប្រគេនព្រហ្មទាននេះ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងបានទ្រង់ស្ដេចយាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ។

ចប់

ប្រយោជន៍ជាតិវែង ប្រយោជន៍ខ្លួនឯងខ្លី

មនុស្សល្ងង់ច្រើនខំប្រយោជន៍ខ្លួន
មនុស្សប្រាជ្ញច្រើនសួនប្រយោជន៍ញាតិ
ប្រយោជន៍ខ្លួនជួនផលប៉ុនអង្គជាត
ប្រយោជន៍ញាតិរាតផលធំទូលាយ ។

ឃ. អ.